# ប្រវត្តិសាស្ត្រវៀតណាម

**ប្រទេសវៀតណាម** ជាប្រទេសនៅអាស៊ីអាគ្នេយ៍ ហៅនៅភាសាវៀតណាម Việt Nam និងនៅភាសាខ្មែរ ជា *ប្រទេសយួន* តែមានមនុស្សមួយចំនួន គិតថាពាក្យយួននេះជាពាក្យដែលសំដៅដល់ការរើសអើងក្នុងន័យអាក្រក់ទៅវិញ។

ប្រទេសវៀតណាមមានព្រំដែនជាប់ជាមួយ សាធារណរដ្ឋប្រជាមានិតចិន នៅខាងជើង ជាប់ជាមួយប្រទេសឡាវ នឹងប៉ែកខាងលិចជាប់នឹងព្រះរាជាណាចក្រកម្ពុជា។ ប្រទេសវៀតណាម មានប្រជាជនប្រមាណ៨០លាននាក់។ រដ្ឋធានីគឺ ទីក្រុងហាណូយ ហើយទីក្រុងដ៏សំខាន់មួយទៀតគឺ ទីក្រុងហូជីមិញ ឬ ទីក្រុងសៃហ្គុន (ទីក្រុងព្រៃនគរ) ស្ថិតនៅប៉ែក ខាងត្បូងនៃប្រទេស។

**ប្រវត្តិសាស្ត្រ**វៀតណាមចាប់ផ្តើមជាង២៧០០ឆ្នាំកន្លងមកហើយ។ ជាយូណាស់មកហើយទំនាក់ទំនងអន្តរជាតិជាប្រវត្តិសាស្ត្រដ៏សំខាន់បំផុត របស់ប្រទេសវៀតណាមគឺប្រទេសចិន។[១] បុរេប្រវត្តិវៀតណាមបានបញ្ចូលបន្ថែម នូវរឿងព្រេងមួយតំណាលអំពីនគរមួយឈ្មោះថា **វ៉ាន ឡាង** (Van Lang) (២៨៥៨–២៧៨៧ម.ស.) ដែលរាប់បញ្ចូលនូវអ្វីដែលតលូវជាតំបន់ស្វយ័តគ័ងស៊ី និងខេត្តគ័ងតុងប្រទេសចិន ក៏ដូចជាមានភាគខាងជើងប្រទេសវៀតណាមដែរ។[២] ក្រោយមកទៀត រាជវង្សបន្តបន្ទាប់ នៅស្រុកចិនបានកាន់កាប់វៀតណាម ដោយផ្ទាល់អស់ជាច្រើនសម័យកាលចាប់ ពីឆ្នាំ ២០៧ ម.គ.រហូតដល់៩៣៨ គ.ស.ពេលនោះវៀតណាមបានទទួលឯករាជ្យមកវិញ ។ [២] វៀតណាមនៅតែជារដ្ឋចំណុះមួយរបស់ចិន ដែលជាប្រទេសជិតខាងដ៏ធំជាងគេ អស់រយៈពេលជាច្រើនបំផុតក្នុងប្រវត្តិសាស្ត្រប្រទេស ក៏ប៉ុន្តែបានរុញច្រានចេញ នូវការលុកលុយរបស់ចិនហើយ ដូចគ្នានេះដែរ ក៏មានការលុកលុយបីដងដោយសំណាក់ពួកម៉ុងហ្គោលរវាងឆ្នាំ ១២៥៥ និង១២៨៥ទៀត។[៣] ព្រះចៅអធិរាជ **ច្រាន ញ៉ាន តុង** (Trần Nhân Tông) ក្រោយមកបានព្រមមកធ្វើជារដ្ឋចំណុះ**រាជវង្សយាន**តាមផ្លូវទូតដើម្បីចៀសវាងជម្លោះតទៅទៀត ។ តំណាក់កាលឯករាជ្យបណ្តោះអាសន្នបានបញ្ចប់ក្នុងពាក់កណ្តាល ដល់ចុងសតវត្សទី១៩ នៅពេលដែលប្រទេសត្រូវបានដាក់ក្រោមអាណានិគមបារាំង (សូមមើលបារាំងឥណ្ឌូចិន)។ កំឡុងសង្គ្រាមលោកលើកទី២ ចក្រពត្តិជប៉ុនបានបណ្តេញពួកបារាំងចេញដើម្បីកាន់កាប់ប្រទេសវៀតណាមវិញ ថែមទាំងពួកគេឃាត់បង្ខាំងរដ្ឋបាលគ្រប់គ្រងរបស់បារាំងកំឡុងការកាន់កាប់របស់ពួកគេទៀត។ បន្ទាប់ពីសង្គ្រាមបារាំងបានព្យាយាមបង្កើតការកាន់កាប់អាណានិគមឡើងវិញក៏ប៉ុន្តែជាចុងក្រោយបានបរាជ័យក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ។ កិច្ចព្រមព្រៀងក្រុងស៊ីណែវ បានបែងចែកប្រទេសជាពីរដោយមានកិច្ចសន្យាក្នុងការបោះឆ្នោតប្រជាមតិដើម្បីបង្រួបបង្រួមប្រទេសឡើងវិញ ។

ក៏ប៉ុន្តែផ្ទុយមកវិញការបង្រួមបង្រួមដោយសន្តិភាពទៅ ជាការបែងចែកដែលដឹកនាំប្រទេសធ្លាក់ចូលសង្គ្រាមវៀតណាមទៅវិញ ។ រយៈពេលនេះដែរ សាធារណរដ្ឋប្រជាមានិតចិន និងសហភាពសូវៀតបានគាំទ្រពួកភាគខាងជើងខណៈនោះដែរ សហរដ្ឋអាមេរិកបានគាំទ្រពួកភាគខាងត្បូង ។ បន្ទាប់ពីមរណភាពប្រជាជនវៀតណាមរាប់លាននាក់ សង្គ្រាមបានបញ្ចប់ជាមួយនឹងការធ្លាក់ក្រុងសៃហ្គុនទៅពួកភាគខាងជើងក្នុងខែ មេសា ឆ្នាំ ១៩៧៥ ។ វៀតណាមបានបង្រួបបង្រួមគ្នាឡើងវិញ ហើយរងទុកដោយសម្ពាធខាងក្រៅបន្ថែមទៀត និងនៅដាច់ឃ្លាតឆ្ងាយ

ពីអន្តរជាតិ ដោយសារតែសង្គ្រាមត្រជាក់កំពុងបន្ត និងការឈ្លានពានរបស់វៀតណាមនៅកម្ពុជា ។ ក្នុងឆ្នាំ១៩៨៦ បក្សកុម្មុយនិស្តវៀតណាមបានផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចរបស់ប្រទេស និងចាប់ផ្តើមកំណែទម្រង់វិស័យឯកជនស្រដៀងទៅ នឹងអ្វីក្នុងប្រទេសចិនដែរ ។ តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ១៩៨០ វៀតណាមពេញចិត្តការលូតលាស់សេដ្ឋកិច្ចដ៏ច្រើនគួរសមដែរ និងការចុះថយនូវសម្ពាធនយោបាយខ្លះ ទោះបីជារបាយការណ៍អំពើពុករលួយបានកើនឡើងផងដែរក៏ដោយ ។

## ១. __នគរដំបូងៗ__

ភស្តុតាងដំបូងបង្អស់ដែលបានបង្កើតសង្គមក្រៅពី**វប្បធម៌ ដុង សឺន**(Đông Sơn)បុរេប្រវត្តិយុគដែកនៅវៀតណាមខាងជើងបានរកឃើញនៅកូឡាក់ (Cổ Loa) ទីក្រុងបុរាណមួយបានតាំងនៅក្បែរហាននួយ(Hà Nội) សព្វថ្ងៃនេះ ។

តាមរយៈទេវកថា ប្រជាជនវៀតណាមបានជាប់ពូជពង្សពីលោកម្ចាស់នាគ**ឡាក់ ឡុង ខ្វាន** (Lạc Long Quân) និងទេពធីតាអមតៈ **អៅ កូ** (Âu Cơ) ។ **ឡាក់ ឡុង ខ្វាន** និង **អៅ កូ** មានកូនប្រុស ១០០នាក់មុនពេលសម្រេចចិត្តចែកផ្លូវគ្នា ។ កូន៥០នាក់ទៅខាងម្តាយតាមតំបន់ភ្នំ និង៥០នាក់ទៀតទៅខាងឪពុកនៅឯសមុទ្រ ។ កូនប្រុសច្បងគេបង្អស់ក្លាយជាខ្សែស្រឡាយទីមួយ នៃក្រុមស្តេចវៀតណាមដំបូងដោយរួបរួមគ្នាជា ក្រុមស្តេចហុង (**ហុង វុង រឺ រាជវង្ស ហុង បាង**) ។ ក្រុមស្តេចហុង ហៅប្រទេសពួកគេ ដែលស្ថិតនៅតាមដីសណ្តទន្លេក្រហម នៅវៀតណាមភាគខាងជើងថា**វ៉ាន ឡាង** ។ ប្រជាជនវ៉ាន ឡាង ត្រូវបានគេស្គាល់ថា ជាពួក **ឡាក់ វៀត** (Lạc Việt) ។

**វ៉ាន ឡាង** ត្រូវបានគេគិតថាធ្លាប់ជាសង្គមមាតាធិបតេយ្យស្រដៀងគ្នាទៅ នឹងសង្គមមាតាធិបតេយ្យមួយចំនួនផ្សេងៗ ជាធម្មតានៅអាស៊ីគ្នេយ៍ និងក្នុងប្រជុំកោះប៉ាស៊ីភិក នៅពេលនោះដែរ។ ស្ថានីយ៍បុរាណវត្ថុផ្សេងៗនៅវៀតណាមខាងជើងដូចជា **ដុង សឺន**(Đông Sơn)មានអាវុធនិងឧបករណ៍ ដែលបានផលិតក្នុងសម័យនោះ ។ ភាគច្រើននៃវត្ថុបុរាណដ៏ល្បីល្បាញទាំងនេះ គឺស្គរសំរិទ្ធធំៗប្រហែលជាបង្កើតឡើងសំរាប់គោលបំណងពិធីបុណ្យ ដែលមានការរចនាស្មុគស្មាញនៅលើផ្ទៃរបស់វា ដែលព័ណនាទិដ្ឋភាពនៃជីវិត ជាមួយនឹង អ្នកចម្បាំង ទូក ផ្ទះសម្បែង បក្សី និងសត្វពាហនៈ ក្នុងរង្វង់ព័ទ្ធជុំវិញព្រះអាទិត្យកំពុងបញ្ចេញរស្មីនៅចំកណ្តាល ។



ផែនទីនៃវ៉ាន ឡាង (Văn Lang), ៥០០ ម.គ.

រឿងព្រេងនិទានជាច្រើនពីសម័យនោះផ្តល់គំនិតខ្លីៗចូលទៅកាន់ជីវិត នៃប្រជាជនសម័យនោះ។ រឿងនិទាននំអង្ករគឺនិយាយអំពីព្រះរាជបុត្រជាអ្នកដែលឈ្នះការប្រកួតធ្វើនំ ទ្រង់ក្រោយមកឈ្នះបានរាជ្យបល្ល័ង្ក ពីព្រោះតែការបង្កើតថ្មីរបស់ទ្រង់គឺនំអង្ករ ដែលឆ្លុះបញ្ចាំងការយល់ដឹងយ៉ាងជ្រៅចំពោះដីគឺជាអាយុជីវិតនៃសេដ្ឋកិច្ច

ការដាំដុះស្រូវ ។ រឿងនិទានហ្គីអុង និយាយអំពីមាណពម្នាក់ទៅធ្វើសង្គ្រាមដើម្បីសង្គ្រោះជាតិដោយពាក់អាវក្រោះដែកជិះសេះក្រោះ និងកាន់ដំបងដែកមួយបានបង្ហាញពីការលុតដែក គឺជាការងារស្មុគស្មាញ។ រឿងនិទានស្នាទិព្វនិយាយអំពីស្នាមួយ ដែលអាចដាក់បានព្រួញបានរាប់ពាន់ដើមបង្ហាញ ពីការប្រើប្រាស់ព្រួញយ៉ាងទូលំទូលាយក្នុងចម្បាំង ។




ផែនទីនៃដីលើកជារង្វង់'ដីក្រហម' ក្នុងប្រទេស កម្ពុជានិងវៀតណាម

ការស្រាវជ្រាវថ្មីៗ បានដោះសោរដោយសាររបកគំហើញនៃដីលើកជារង្វង់បែបសិប្បនិមិត្ត ក្នុងតំបន់មួយចំនួន នៃវៀតណាមខាងត្បូងសព្វថ្ងៃ ហើយឆ្លងទៅដល់ព្រំដែននៃប្រទេសកម្ពុជាទៀត ។ សំណល់បុរាណវត្ថុទាំងនេះត្រូវប៉ាន់ស្មានថាជាអង្គរប្បធម៌ សង្គម និងសេដ្ឋកិច្ចកាលពី សហវត្សទី១ម.គ. ។[៨]

នៅសតវត្សទី៣ម.គ. ពួកវៀត (Viet)ផ្សេងទៀត **ឪ វៀត** (Au Viet=Âu Việt) បានធ្វើចំនាកស្រុកពីចិនភាគខាងត្បូងសព្វថ្ងៃនេះ មកតំបន់ដីសណ្តទន្លេក្រហម ហើយនៅលាយឡំ ជាមួយប្រជាជនដើម "**វ៉ាន ឡាង** ។ ក្នុងឆ្នាំ២៥៨ម.គ. រាជាណាចក្រថ្មីមួយ **ឪ ឡាក់** (Âu Lạc) បានលេចត្រដែតឡើង តាមការរួបរួមគ្នានៃពួក **ឪ វៀត** (Âu Lạc) និងពួក **ឡាក់ វៀត**(Lạc Việt)ដែលមាន**ថាច់ ផាន់** (Thục Phán)ដែលប្រកាសខ្លួនឯងថាជា ***ស្តេច អាន ដុង វុង*** (An Dương Vương) ។ នៅឯរាជធានីទ្រង់ **កូ ឡូវ** (Cổ Loa) ទ្រង់បានកសាងកំផែងរាងមូលព័ទ្ធជុំវិញក្រុងជាច្រើនដើម្បីគោលបំណងបង្ការការពារ ។ កំផែងទាំងនេះ រួមមានពួកខ្មាន់ធ្នូ **ឪ ឡាក់**ដែលស្ទាត់ជំនាញ ដែលចាំថែរក្សាការពាររាជធានីឲមានសុវត្ថិភាព ពីពួកឈ្លានពានភ្លាមៗ ។ ក៏ប៉ុន្តែ វាក៏បានផ្តល់ការកើនឡើងនូវករណីចារកិច្ចសម្ងាត់ ដែលបានកត់ទុកលើកទីមួយក្នុងប្រវត្តិសាស្ត្រជនជាតិវៀតណាម ដែលជាលទ្ធផលនៃការដួលរលំនៃស្តេច **អាន ដុង វុង** ។

នៅឆ្នាំ២០៧ ម.គ. ស្តេចត្រាញ់ចិនដ៏មានមហិច្ឆតាម្នាក់ ដែលមាននាមថា **ទ្រៀវ ដា** (Triệu Đà,ចិន: **ចាវ ធូវ** = Zhao Tuo ) បានកម្ចាត់ ស្តេច អាន ដុង វុង ដោយមានកូនប្រុសលោក **ទ្រុង ធុយ** (Trọng Thủy ,ចិន: ចុងស៊ឺ = Zhong Shi) ដើរតួជាគីញសម្ងាត់ម្នាក់ក្រោយមកបានរៀបអភិសេកជាមួយនឹងបុត្រី អាន ដុង វុង ។ ទ្រៀវ ដា បានបញ្ចូល **ឪ ឡាក់** ក្រោមការត្រួតត្រារបស់ខ្លួន ដែលមានមូលដ្ឋាននៅគ័ងតុងបច្ចុប្បន្ន ប្រទេសចិនភាគខាងត្បូងក្រោយមកបានប្រកាសខ្លួនឯងជាស្តេចនៃរាជាណាចក្រឯករាជ្យមួយ **ណាមវៀត** (Nam Việt) (ចិន:南越, ណានយៀក = Nan Yue) ។ **ទ្រុង ធុយ** រាជបុត្រម្កុដរាជដែលគិតទុកជាមុន បានលង់ខ្លួន នៅ **កូ ឡូវ** ក្រោយពីវិប្បដិសារីចំពោះការចូលទីវង្គត់នៃមហេសីទ្រង់ ក្នុងសង្គ្រាម ។

ជនជាតិវៀតណាមខ្លះចាត់ទុក ការគ្រប់គ្រងរបស់**ទ្រៀវ**ជាសម័យកាលនៃការត្រួតត្រារបស់ចិនមួយដែរដោយហេតុថា ទ្រៀវ ដាជាអតីតមេទ័ព**ឈិន** ។ អ្នកដ៏ទៃផ្សេងទៀតចាត់ទុកថាវាជាសម័យមួយ នៃឯករាជ្យភាពរបស់វៀត ពេល ដែលគ្រួសារទ្រៀវ នៅណាម វៀតត្រូវបាននៅលាយឡំគ្នាទៅ នឹងវប្បធម៌ក្នុងតំបន់ ។ ពួកគេបានកាន់

កាប់ដោយឯករាជ្យនូវអ្វី ដែលក្រោយមកទៀតរួម នឹង**រាជវង្សហាន**ចិន ។ នៅចំនុចនោះ **ទ្រៀវ ដា** ថែមទាំងប្រកាសខ្លួនថាជាព្រះចៅអធិរាជ ស្មើនឹងព្រះចៅអធិរាជហានចិននៅភាគខាងជើង ។

## ២. សម័យកាលនៃការត្រួតត្រារបស់ចិន (១១១ម.គ.- ៩៣៨ គ.ស.)

ក្នុងឆ្នាំ១១១ម.គ. កងទ័ពចិនបានឈ្លានពាន **ណាម វៀត** ហើយបង្កើតឡើងតំបន់ថ្មីៗ **គៀវ ឈី** (Giao Chỉ,ចិន:交趾 *pinyin:* ជាវជឺ, ឥឡូវដីសណ្ដទន្លេក្រហម ) គូអ៊ុ ឆាន (Cửu Chân) ពី**ថាញ់ ហ៊ា** (Thanh Hoá) ដល់ ហា ទៀង (Hà Tĩnh) និង ញ៉ាត ណាម (Nhật Nam) បច្ចុប្បន្ននេះ ពី**ខ្វាង ប៊ិញ** (Quảng Bình) ដល់ **ហ្វេ** (Huế) សព្វថ្ងៃនេះ ។ ពេលនោះពួកចិនដែលជាថៅហ្វាយខេត្ត និងមន្ត្រីកំពូលៗ ដែលជាអភិជនដើមកំណើតវៀតណាម (ឡាក់ ហៅ = Lạc Hầu, ឡាក់ ទួង = Lạc Tướng) នៅតែបានគ្រប់គ្រងតាមតំបន់ភ្នំខ្ពស់ៗខ្លះៗដែរ ។

ក្នុងឆ្នាំ៤០ គ.ស. ការបះបោរដ៏ជោគជ័យមួយប្រឆាំងនឹងការគ្រប់គ្រងដ៏យង់ឃ្នងដោយថៅហ្វាយខេត្តហាន តូ ឌិញ (Tô Định, ចិន:ស៊ូ ទីង = 蘇定 *pinyin:* Sū Dìng) ដែលបានដឹកនាំដោយ ស្ត្រីអភិជនម្នាក់ **ទ្រុង ថ្រាក់** (Trưng Trắc) និងបងប្អូនរបស់នាង **ទ្រុង ញី** (Trưng Nhị) បានកាន់កាប់ឡើងវិញនូវរដ្ឋទាំង៦៥ (រួមទាំងគ័ងស៊ីសម័យទំនើបនេះ) ហើយ ទ្រុង ថ្រាក់ បានក្លាយជាម្ចាស់ក្សត្រី **ទ្រុង នូ វុង** (Trưng Nữ Vương) ។ ក្នុងឆ្នាំ៤២គ.ស. ព្រះចៅអធិរាជ**គ័ងអ៊ូ**នៃរាជវង្សហាន បានបញ្ជូនមេទ័ពដ៏ល្បីរបស់ព្រះអង្គ **ម៉ា វៀន** (Mã Viện, ចិន:ម៉ាយាន = Ma Yuan) ដើម្បីបង្ក្រាបការបះបោរ ។ បន្ទាប់ពីយុទ្ធនាការយ៉ាងស្មុគស្មាញមួយមក ម៉ា យាន បានកម្ចាត់ម្ចាស់ក្សត្រីទ្រុង ដែលក្រោយមកទ្រង់បានធ្វើអត្តឃាតខ្លួនឯងសុគតទៅ ។ មកទល់សព្វថ្ងៃ បងប្អូនស្រីត្រកូលទ្រុង ត្រូវបានដឹងនៅក្នុងប្រទេសវៀតណាមថាជានិមិត្តរូបជាតិនៃស្ត្រីវៀតណាម ។ ដោយបានរៀនមេរៀនមួយពីពួកអ្នកបះបោរត្រកូលទ្រុងមក ហាន និងរាជវង្សចិនដែលសោយរាជ្យបន្តៗទៀត បានដាក់វិធានការ ដើម្បីកាត់បន្ថយអំនាចនៃពួកអភិជនវៀតណាមចេញ ។ ឥស្សរជនវៀតណាម អាចនឹងបានបង្ខិតបង្ខំឲរស់នៅលាយឡំក្នុងនយោបាយ និងវប្បធ៌មចិន ។ យ៉ាងណាក៏ដោយ ស្ត្រីម្នាក់ផ្សេងទៀត **ទ្រៀវ ធី ទ្រិញ** (Triệu Thị Trinh) ដែលគេបានស្គាល់ថជាទូទៅថាជាអ្នកស្រីទ្រឿវ (បា ទ្រៀវ = Bà Triệu) បានដឹកនាំការបះបោរមួយទៀតដែលបន្តរហូតដល់ឆ្នាំ ២៤៨ គ.ស. ។

កំឡុងរាជវង្សថាង វៀតណាមត្រូវបានហៅថា **អណ្ណាម** (គៀវ ចូវ = Giao Châu) រហូតដល់ដើមសតវត្សទី១០នៃ គ.ស. ។ **គៀវឈី** (Giao Chỉ) (ដែលមានរាជធានីនៅក្បែរៗខេត្តបាក់ និញ = Bắc Ninh សព្វថ្ងៃនេះ ) បានក្លាយជាទីប្រជុំជនដោះដូរពាណិជ្ជកម្មយ៉ាងរស់រវើក ដែលទទួលបានទំនិញពីសមុទ្រខាងត្បូង ។ *ប្រវត្តិសាស្ត្រនៃចុងរាជវង្សហាន* (ហៅ ហាន ធូ = Hậu Hán Thư, ចិន:ហៅ ហានស៊ូ = Hou Hanshu) បានកត់ត្រាថាក្នុងឆ្នាំ ១៦៦ គ.ស. បេសកជនទីមួយមកពីចក្រភពរ៉ូម ទៅដល់ប្រទេសចិនតាមរយៈច្រកនេះ ហើយនិងពួកឈ្មួញក៏មកតាមច្រកនេះយ៉ាងរហ័សដែរ ។ *រឿងនិទានវ៉ី (Wei)* សតវត្សទី៣ (ង៉ុយ លុក = Ngụy Lục, "វ៉ីលូ = Weilue") បានបកស្រាយអំពី*ផ្លូវទឹក*មួយ (ទន្លេក្រហម) ពីជាវជី ទៅកាន់អ្វីដែល គឺជាយូណានខាងត្បូងឥឡូវនេះ ។ ពីទីនោះទៅ ទំនិញត្រូវបានយកឡើងដីគោកទៅពាសពេញប្រទេសចិន កាត់តាមតំបន់មួយចំនួន នៃឃុនមិង(Kunming) និងឆឹងទូ(Chengdu) សម័យថ្មីនេះ ។

នៅក្នុងពេលតំណាលគ្នានេះដែរ នៅវៀតណាមកណ្ដាលបច្ចុប្បនេះ ធ្លាប់មានការបះបោរបានសម្រេចមួយនៃពួកជនជាតិចាម ។ រាជវង្សចិនខ្លះ បានហៅថា លីន អ៊ី (Lin-Yi) (ភូមិលីន) ។ ពេលក្រោយមកទៀតបានក្លាយជានគរមួយដ៏មានអំនាច ចាម្ប៉ា ដែលលាតសន្ធឹងពី ខ្វាង ប៊ិញ (Quảng Bình) ដល់ ផាន់ ធាត (Phan Thiết, ឥឡូវ ប៊ិញ ធួន = Bình Thuận) ។

ក្នុងសម័យរវាងការចាប់ផ្ដើមយុគនៃការបែកបាក់ប្រទេសចិនដល់សម័យរាជវង្សថាង ពួកអ្នកបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់ចិនជាច្រើនបានចូលរួមគ្នាដូចជា ពួក**លី ប៊ុន** (Lý Bôn)និងមេទ័ព និងទាយាទរបស់លោក **ទ្រៀវ ខ្វាង ផាច់** (Triệu Quang Phục) និងក្រុមពួកម៉ាយ **ថាច់ លាន់** (Mai Thúc Loan) និង**ផុង ហុង** (Phùng Hưng) ។ ក្នុងចំនោមពួកគេទាំងអស់ ជាចុងក្រោយបានបរាជ័យទាំងអស់ ក៏ប៉ុន្តែគួរឲកត់សំគាល់ខ្លាំងបំផុតគឺ លី ប៊ុន និងទ្រៀវ ខ្វាង ផាច់ រាជវង្សលីដែលនាំមុខគេរបស់ពួកគេ បានកាន់កាប់អស់រយៈពេលកន្លះសតវត្ស (៥៤៤ គ.ស.ដល់ ៦០២ គ.ស.) មុនពេលរាជវង្សសួយចិន បានធ្វើសញ្ជ័យអាណាចក្រ វ៉ាន សួន (Vạn Xuân) របស់ពួកគេម្ដងទៀត ។

### ៣. <u>ឯករាជ្យដើមដំបូង (៩៣៨ គ.ស. - ១០០៩ គ.ស.)</u>

នៅដើមសតវត្សទី១០ ពេលដែលចិនបានបែកខ្ញែកខាងនយោបាយ ពួកលោកម្ចាស់ដែលស្នងបន្តពីគ្រួសារ **ខាច់** (Khúc) ដើរតាមដោយ **ដុង ឌិញ ង៉េ** (Dương Đình Nghệ) បានកាន់កាប់ គៀវ ចូវ (Giao Châu) ដោយស្វយ័តភាពក្រោមពួក**ថាង** ដែលមានគោរម្យងារថា **ទៀត ដូ ស៊ូ** (Tiết Độ Sứ) លោកម្ចាស់គុណធំម ក៏ប៉ុន្តែក៏ឈប់ភ្លាមទៅ ដោយប្រកាសពួកខ្លួនថាពួកស្ដេច ។

ក្នុងឆ្នាំ៩៣៨ ហានខាងត្បូង បានបញ្ជូនកងទ័ពដើម្បី ធ្វើសញ្ជ័យតំបន់ស្វយ័ត គៀវ ចូវ (Giao Châu) ។ **ង៉ោ គុយយិង** (Ngô Quyền) កូនប្រសារ របស់**ដុង ឌិញ ង៉េ** បានកម្ចាត់កងសំពៅហានខាងត្បូងនៅឯសមរភូមិទន្លេ បាច់ ដាង (៩៣៨) (Bạch Đằng) ។ លោកក្រោយមកបានប្រកាសខ្លួនជា**ព្រះចៅង៉ោ** និងចាប់ផ្ដើមយ៉ាងមានប្រសិទ្ធិភាពនូវយុគ នៃឯករាជ្យភាពរបស់វៀតណាម ។

ការចូលទីវង្គត់ដោយមិនត្រូវកាលៈទេសៈរបស់ទ្រង់ ង៉ោ គុយយិន បន្ទាប់ពីរជ្ជកាលដ៏ខ្លីបានហុចជាលទ្ធផលក្នុងការដណ្ដើមអំនាចគ្នាសោយរាជ្យ បង្កជាសង្គ្រាមផ្ទៃក្នុងដ៏ធំលើកទីមួយក្នុងប្រទេស គឺជាការឡើងដៃនៃស្ដេចក្រាញ់ទាំងដប់ពីរ (លាន់ ថាប ញី ស៊ូ ខ្វាន = Loạn Thập Nhị Sứ Quân) ។ សង្គ្រាមបានបន្តពីឆ្នាំ៩៤៥ គ.ស. ដល់ ៩៦៧ គ.ស. នៅពេលដែលបក្សពួកដឹកនាំដោយ **ឌិញ បូ លិញ** (Đinh Bộ Lĩnh) បានកម្ចាត់ពួកស្ដេចក្រាញ់ដ៏ទៃៗ ហើយក៏បង្រួបបង្រួមប្រទេសឡើងវិញ ។ លោកម្ចាស់ឌិញ បានស្ថាបនិករាជវង្សឌិញ (Đinh) និងប្រកាសខ្លួនថាជាព្រះចៅអធិរាជទីមួយ (**ធាន វ៉ាង** = Tiên Hoàng) នៃ ដៃ កូ វៀត (Đại Cồ Việt) (**ហាន ធូ** = Hán tự:大瞿越 ដែលមានន័យចំថា "មហាប្រទេសវៀត") ដែលមានរាជធានី នៅវ៉ា លូ (Hoa Lư) (សម័យថ្មីនេះ និញ ប៊ិញ = Ninh Bình) ។ យ៉ាងណាក៏ដោយរាជវង្សសុងចិនបានទទួលស្គាល់ទ្រង់ជាផ្លូវការត្រឹមតែជាព្រះអង្គម្ចាស់**ជាវជឺ** (គៀវ ឈី ខ្វាន វុង = Giao Chỉ Quận Vương)ប៉ុណ្ណោះ ។ ព្រះចៅអធិរាជឌិញ បានបញ្ចូលច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរឹង

ដើម្បីទប់ស្កាត់ភាពចលាចលកើតឡើងម្តងទៀត ។ ព្រះអង្គបានព្យាយាមបង្កើតសម្ព័ន្ធភាព ដោយផ្តល់គោរមងារជាម្ចាស់ក្សត្រីទៅ៥ស្ត្រីប្រាំនាក់មកពីគ្រួសារ ដែលមានអំនាចខ្លាំងបំផុត ។

ក្នុង៩៧៩ គ.ស. ព្រះចៅអធិរាជ ឌិញ បូ លិញ និងរជ្ជទាយាទ (ព្រះអង្គម្ចាស់មុដរាជ) ឌិញ លាន ត្រូវបានគេលួចធ្វើឃាត បន្សល់ទុកព្រះបុត្រារបស់ទ្រង់ដែលនៅមានព្រះជន្មកណ្តោចកណ្តែង ឌិញ ធាន់ (Đinh Toàn) ដែលមានព្រះជន្ម៦ព្រះវស្សា ទទួលស្នងរាជ្យបល្ល័ង្កបន្ត ។ ដោយទាញបានប្រយោជន៍ពីស្ថានភាពនេះ **រាជវង្សសុង** ចិនបានធ្វើការលុកលុយ ដៃ កូ វៀត (Đại Cồ Việt) ។ ដោយប្រឈមមុខដូចគ្នា នូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមួយចំពោះឯករាជ្យជាតិ មេបញ្ជាការកងទ័ពវាំងទាំងដប់ (ថាប ដាវ ទួង ខ្វាន = Thập Đạo Tướng Quân) **ឡេ ហ៊ាន់** (Lê Hoàn) បានជ្រែករាជ្យ ដោយស្ថាបនាអតីត**រាជវង្សឡេ** ។ ជាអ្នកកលយុទ្ធយោធាដ៏មានសមត្ថភាព ឡេ ហ៊ាន់ បានយល់ដឹងនៅគ្រោះថ្នាក់ ដោយជាប់ទាក់ទងនឹកងទ័ពចិនដ៏ខ្លាំងពូកែបានធ្វើដំណើរចុះមក ដូច្នេះលោកក៏បានធ្វើល្បិចជាមានកងទ័ពឈ្លានពាននៅឯច្រក ឈី ឡាង (Chi Lăng) ក្រោយមកទៀតក៏ព័ទ្ធស្ទាក់វាយឆ្មក់ និងកាប់សម្លាប់មេបញ្ជាការពួកគេអស់ទៅ ភ្លាមនោះក៏បញ្ចប់នូវការគំរាមកំហែងដល់ប្រទេសដ៏ក្មេងខ្ចីរបស់លោក នៅឆ្នាំ ៩៨១គ.ស។ រាជវង្សសុងបានដកទ័ពទៅយ៉ាងនេះក្តីក៏នៅតែទទួលស្គាល់ ឡេ ហ៊ាន់ ត្រឹមតែជាព្រះអង្គម្ចាស់ជាវជីលុះ១២ឆ្នាំក្រោយមកទៀតផ្ទុយមកវិញលោកត្រូវបានគេអះអាង ក្នុងអាណាចក្ររបស់លោកថាជាព្រះចៅអធិរាជ ដាយ ហាញ់ (ដាយ ហាញ់ ហួង ដេ = Đại Hành Hoàng Đế) ។ ព្រះចៅអធិរាជ ឡេ ហ៊ាន់ ក៏ជាស្តេចវៀតណាមទីមួយដែរ ដែលចាប់ផ្តើមការពង្រីកទឹកដីឆ្ពោះមកភាគខាងត្បូងទល់នឹងនគរ**ចាម្ប៉ា** ។

ការចូលទីវង្គត់នៃព្រះចៅអធិរាជ **ឡេ ហ៊ាន់**ក្នុងឆ្នាំ ១០០៥ គ.ស. បានហុចលទ្ធផលជាជម្លោះគ្នាឯង ដើម្បីដណ្តើមរាជបល្ល័ង្ក ក្នុងចំនោមព្រះរាជបុត្រារបស់ព្រះអង្គ ។ អ្នកឈ្នះចុងក្រោយ **ឡេ ឡុង ឌិញ** (Lê Long Đĩnh) បានក្លាយជាស្តេចផ្តាច់ការ ដែលគេបានស្គាល់ច្រើនបំផុតក្នុងប្រវត្តិសាស្ត្រវៀតណាម ។ ទ្រង់បានដាក់ទារុណកម្មចំពោះអ្នកទោសយ៉ាងឃោរឃៅដើម្បីការកំសាន្តផ្ទាល់របស់ព្រះអង្គ ហើយផ្តេកផ្តួលខ្លួនទ្រង់ក្នុងរឿងស្រីញីយ៉ាងបែកធ្លុង ។ មកទល់នឹងព្រះជន្មដ៏ខ្ចីរបស់ទ្រង់ – ទ្រង់បានសុគតនៅព្រះជន្ម២៤ – **ឡេ ឡុង ឌិញ** បានធ្លាក់ខ្លួនព្រះឈួនធ្ងន់ ដែលទ្រង់បានដួលលើដី នៅពេលកំពុងប្រជុំជាមួយមន្ត្រីព្រះអង្គ នៅក្នុងរាជវាំង ។

### ៤. <u>សម័យឯករាជ្យនៃដាយវៀត (១០១០ គ.ស.– ១៥២៧ គ.ស.)</u>

នៅពេលដែលស្តេច **ឡេ ឡុង ឌិញ** បានសុគតទៅក្នុងឆ្នាំ១០០៩ គ.ស. មេទ័ពការពាររាជវាំងដែលមានឈ្មោះថា **លី កុង អួន** (Lý Công Uẩn) ត្រូវបានតែងតាំងដោយពួកមន្ត្រីវាំង៥ឡើងសោយរាជ្យ ហើយក៏បង្កើតបានជា**រាជវង្សលី** ។ ព្រឹត្តិការណ៍នេះត្រូវបានចាត់ទុកថាជាកាផ្តើម នៃយុគមាសក្នុងប្រវត្តិសាស្ត្រវៀតណាម ជាមួយនឹងក្រុមរាជវង្សដ៏ឆ្នើមៗល្បីៗបន្តបន្ទាប់គ្នា ។ វិធីដែល **លី កុង អួន** ស្នងរាជ្យបល្ល័ង្កផ្ទុយខុស ពីធម្មតាក្នុងប្រវត្តិសាស្ត្រវៀតណាម ។ បើតាមឋានៈជាមេបញ្ជាការជាន់ខ្ពស់កំពុងតែឈរជើងនៅរាជធានី លោកមានគ្រប់ឱកាសទាំងអស់ដើម្បីដណ្តើមឈោងយកអំនាច កំឡុងពេលប៉ុន្មានឆ្នាំជ្រួលច្របល់បន្ទាប់ពីការសោយទីវង្គត់របស់ព្រះចៅអធិរាជ ឡេ ហ៊ាន់ ក៏ប៉ុន្តែមិនសាកសមទេ ដើម្បីធ្វើដូច្នេះក្រៅពីហេតុផល នៃការគោរពតួនាទីនោះទេ ។ លោកយកវិធីមួយដោយការ*ជ្រើសរើស*ដោយពួកមន្ត្រីក្នុងវាំងបន្ទាប់ពីការជជែកពិភាក្សាខ្លះមុនពេលមានការព្រមព្រៀងបានឈានមកដល់ ។

**លី កុង អួន** បានបញ្ជាក់ថាជា **លី ថាយ ថូ** ក្រោយពីសុគត បានផ្លាស់ឈ្មោះប្រទេសទៅជា **ដាយ វៀត** (ហាន ធូ = Hán tự: 大越; ដែលមានន័យចំថា*មហាវៀត*) ។ រាជវង្សលីត្រូវបានគេសរសើរ ចំពោះកាចាក់គ្រឹះយ៉ាងរឹងមាំដោយមានទស្សនៈវិស័យយុទ្ធសាស្ត្រសំរាប់ជនជាតិវៀតណាម ។ ដោយបន្សល់នៅ **ហូ លូ** (Hoa Lư) បន្ទាយធម្មជាតិព័ទ្ធទៅដោយភ្នំ និងទន្លេ លី កុង អួន បានផ្លាស់រាជវាំងទ្រង់ទៅតាំងរាជធានីថ្មីនៅ**ហាណូយ**បច្ចុប្បន្ននេះ ហើយបានហៅថា **ថាង ឡុង** (Thăng Long) (នាគរះ) ។ ដូច្នេះហើយ **លី កុង អួន** បានងាកចេញពីគំនិតការពារដោយកងទ័ពនៃបុព្វការីជនមុនៗរបស់លោក ហើយបានប្រមើលលើសេដ្ឋកិច្ចរឹងមាំជាគន្លឹះ សំរាប់អាយុជីវិតរបស់ប្រទេសជាតិវិញ ។ ពួកក្រុមស្តេចលីដែលសោយរាជ្យបន្តបន្ទាប់ បានបន្តបង្កើយសមិទ្ធិផលដ៏វែងឆ្ងាយៈការសាងនូវប្រព័ន្ធទំនប់ទឹកដើម្បីគាំពារដល់តំបន់ផលិតកម្មស្រូវ ការស្ថាបនា **ខ្វុក ធូ ហ្គាម** (Quốc Tử Giám) សាកលវិទ្យាល័យជាន់ខ្ពស់ទីមួយ ដោយមានធ្វើការប្រលងជាទៀងទាត់ដើម្បីជ្រើសរើសជនសាមញ្ញ ដែលមានសមត្ថភាពដើម្បីទទួលបានតំនែងក្នុងរាជការរយៈពេលបីឆ្នាំម្តង រៀបចំប្រព័ន្ធពន្ធដារថ្មី និងការបង្កើតឡើងការព្យាបាលដោយមនុស្សធម៌ចំពោះអ្នកទោស ។ ស្ត្រីៗក៏បានកាន់តួនាទីសំខាន់ដែរ ក្នុងសង្គមលីជាពួកស្រីស្នំដែលទទួលបន្ទុកខាងប្រមូលពន្ធ ។ រាជវង្សលីក៏បានលើកតំកើង**ព្រះពុទ្ធសាសនា** ក៏ប៉ុន្តែបានថែរក្សាលក្ខណៈពហុនិយមចំពោះប្រព័ន្ធទស្សនៈធំៗបីនៅពេលនោះៈពុទ្ធនិយម **ខុងជឺនិយម** និង**តាវនិយម** ។ កំឡុងរាជវង្សលី **រាជវង្សសុង**ចិនបានទទួលស្គាល់ជាផ្លូវការនូវមហាក្សត្រ ដាយ វៀត ជាស្តេច **គៀវ ឈី** (Giao Chỉ) (គៀវ ឈី ខ្វាន វុង = Giao Chỉ Quận Vương) ។

រាជវង្សលីធ្លាប់មានសង្គ្រាមពីរធំៗជាមួយ **សុង**ចិន និងមានចម្បាំងតិចតួចទល់នឹងប្រទេស**ចាម្ប៉ា**ជិតខាងនៅភាគខាងត្បូង ។ សមរភូមិគួរឲកត់សំគាល់បំផុតបានប្រព្រឹត្តទៅនៅលើទឹកដីចិន ១០៧៥ គ.ស. ។ នៅពេលដែលដឹងថា មានការលុកលុយរបស់សុងដ៏ធំអស្ចារ្យ ទាហាន និងកងទ័ពជើងទឹកលីសរុបទៅប្រហែល ១០០,០០០នាក់ក្រោមការបញ្ជារបស់ **លី ធួង គៀត** (Lý Thường Kiệt) **តុង ដាន** (Tông Đản) បានប្រើប្រត្តិបត្តិការដែលប្រកបដោយមហិច្ឆតាដើម្បីកម្ទេចឲបានមុននូវការដាក់ពង្រាយកងទ័ពរបស់សុងបីកងពលនៅឯ **យ៉ុង ចូវ** (Yong Zhou), **ឈិន ចូវ** (Qin Zhou) និង**លៀន ចូវ** (Lian Zhou) សម័យបច្ចុប្បន្ន **គ័ងតុង** (Guangdong) និង**គ័ងស៊ី** (Guangxi)ហើយនិងបានកាប់សម្លាប់ជនជាតិចិន ១០០,០០០ នាក់ទៀត ។ រាជវង្សសុងបាននាំមកដោយកំហឹងសងសឹកនិងឈ្លានពាន ដាយ វៀត ក្នុងឆ្នាំ១០៧៦ ក៏ប៉ុន្តែកងទ័ពសុងត្រូវបានដកថយទៅវិញនៅឯ**សមរភូមិទន្លេ ញូង៉ុយយិត** (Như Nguyệt) ដែលគេស្គាល់ជាទូទៅថាជាទន្លេកៅ ឥឡូវស្ថិតក្នុងខេត្ត បាក់ និញ (Bắc Ninh) ប្រហែលជា៤០ គ.ម.ពីរដ្ឋធានីថ្មី ហាណូយ ។




អាស៊ីអាគ្នេយ៍ប្រហែលឆ្នាំ១០១០ គ.ស. ។ ទឹកដី ដាយ វៀត ព៌ណលឿង, ចាម្ប៉ាព៌ណបៃតង និងចក្រភពខ្មែរ ព៌ណក្រាវ

មិនថាខាងណាទេក៏មិនអាចយកឈ្នះគ្នាបាន ដូច្នេះរាជវង្សលីបានសុំឲមានការផ្អាកសង្គ្រាម ដែលរាជវង្សសុងក៏បានយល់ព្រមដែរ ។

មកទល់នឹងចុងនៃរាជវង្សលី មន្ត្រីរាជវាំងដ៏មានអំនាចម្នាក់មានឈ្មោះថា **ច្រាន់ ធូ ដុ** (Trần Thủ Độ) បានបង្ខំឲស្តេច **លី ហួ តុង** (Lý Huệ Tông) ក្លាយជាព្រះសង្ឃពុទ្ធសាសនា និង**លី ជៀវ ហ៊ាង់** (Lý Chiêu Hoàng) បុត្រីដ៏ក្មេងវ័យរបស់ **ហួ តុង** បានក្លាយម្ចាស់ក្សត្រី ។ **ច្រាន់ ធូ ដុ** ក្រោយមកបានរៀបចំរៀបអភិសេក **ជៀវ ហ៊ាង់** ជាមួយនឹងក្មួយប្រុសរបស់លោក **ច្រាន់ កាញ់** (Trần Cảnh) ហើយនៅទីបំផុតក៏បានរាជ្យបល្ល័ង្ករួចផ្ទេរទៅឲ **ច្រាន់ កាញ់** ដូចនេះហើយក៏បានចាប់ផ្តើម រាជវង្សច្រាន់ (Trần) ។ **ច្រាន់ ធូ ដុ** បានបោសសំអាតសមាជិកនៃពួកអភិជនត្រកូលលីដោយជោគជ័យ ព្រះអង្គម្ចាស់លីខ្លះក៏បានភៀសព្រះកាយទៅប្រទេសកូរ៉េ រួមមាន **លី កុង ទួង** (Lý Long Tường)ជាដើម ។



ស្លាកសមរភូមិនៃរាជវង្សច្រាន់

បន្ទាប់ពីការបណ្តេញចេញ ភាគច្រើនពួកស្តេចត្រាន់ បានដឹកនាំប្រទេសក្នុងសភាពស្រដៀងគ្នាទៅនឹងពួកស្តេចលីដែរ ។ សមិទ្ធិផលសម្រេចរាជវង្សច្រាន់ដែលគួរឲកត់សំគាល់រួមមានការបង្កើតថ្មីនៃប្រព័ន្ធកត់ត្រាអត្រាប្រជាជនពឹងផ្អែកនៅថ្នាក់ភូមិ ការចងក្រងប្រវត្តិសាស្ត្រ ដាយ វៀតជាផ្លូវការ៣០ខ្សែ (ដាយ **វៀត ស៊ុ គី** = Đại Việt Sử Ký) ដោយ **ឡេ វ៉ាន់ ហ៊ុ** (Lê Văn Hưu) ហើយនិងការបង្កើតឡើងនូវលក្ខណៈនៃអក្សរ**ណូម** (Nôm) ប្រព័ន្ធសំនេរនៃភាសាវៀតណាម ។ រាជវង្សច្រាន់ក៏បានអនុម័តរបៀបថ្មីតែមួយគត់ដើម្បីបង្រៀនពួកស្តេចថ្មីៗៈពេលស្តេចមួយអង្គដល់វ័យចាស់ឆ្នាំ ទ្រង់នឹងលះបង់រាជបល្ល័ង្កទៅឲរជ្ជទាយាទ (រាជបុត្រស្នងរាជ្យ) ក៏ប៉ុន្តែកាន់គោរម្យងារជាព្រះចៅឧត្តមបរមរាជាធិរាជ (ថាយ ធ៉ង ហួង = Thái Thượng Hoàng) ដើរតួជា អ្នកផ្តល់ដំបូន្មានដល់ព្រះចៅអធិរាជថ្មី ។

## ៤.១. <u>ការលុកលុយឈ្លានពានរបស់ម៉ុងហ្គោល</u>

កំឡុងរាជវង្សច្រាន់ កងទ័ពនៃចក្រភពម៉ុងហ្គោល ក្រោមការដឹកនាំរបស់**ម៉ុងខឺ ខាន់** (Mongke Khan) និង**គូប៊ីឡៃ ខាន់** (Kublai Khan) ស្ថាបនិករាជវង្សយានបានលុកលុយវៀតណាមក្នុងឆ្នាំ១២៥៧ គ.ស. ១២៨៤ គ.ស. និង១២៨៨ គ.ស. ។ ដាយ វៀត បានវាយបកគ្រប់ការវាយប្រហារនៃពួកយានទាំងអស់កំឡុងរជ្ជកាលនៃ**គូប៊ីឡៃ ខាន់** ។ គន្លឹះចំពោះជ័យជំនះរបស់ដាយ វៀតគឺត្រូវចៀសវាងកម្លាំងរបស់ពួកម៉ុងហ្គោលនៅសមរភូមិទីវាល និងបន្ទាយក្រុង រាជវាំងពួកច្រាន់បានបោះចោលរាជធានី និងទីក្រុងជាច្រើន ។ ពួកម៉ុងហ្គោលក្រោយមកត្រូវបានគបគយ៉ាងដាច់ណាត់ត្រង់ចំនុចខ្សោយរបស់ពួកគេ ដែលជាសមរភូមិនៅក្នុងតំបន់វាលភក់មួយចំនួន ដូចជា **ឆួង ដួង** (Chương Dương) **ហែម ទូ** (Hàm Tử) **វ៉ាន់ គៀប** (Vạn Kiếp) និងតាមដងទន្លេជាច្រើន ដូចជាវ៉ាន់ ដូន (Vân Đồn) និងបាច់ ដាង (Bạch Đằng) ។ ពួកម៉ុងហ្គោលក៏រងទុក្ខដោយសារជំងឺតំបន់ក្តៅ និងការ

បាត់បង់នូវការផ្គត់ផ្គង់ ដោយការវាយឆ្មក់របស់កងទ័ពច្រាន់ ។ សង្គ្រាមយាន-ច្រាន់បានឈានទៅ ដល់កម្រិតកំពូល នៅពេលកងសំពៅយានកំពុងដកថយដោយត្រូវបានបំផ្លាញដប់ដងនៅសមរភូមិ **បាច់ ដាង** (១២៨៨) (Bạch Đằng) ។ អ្នកមុខការកាន់កងទ័ពពីក្រោយជោគជ័យរបស់ ដាយ វៀត គឺមេបញ្ជាការកងទ័ង **ច្រាន់ គុក ទួន** (Trần Quốc Tuấn) ដែលគេនិយមស្គាល់ទៀតថាជា **ច្រាន់ ហុង ដាវ** (Trần Hưng Đạo) ។ ដើម្បីចៀសវាងយុទ្ធនាការសឹក ដែលប្រកបដោយមហន្តរាយ ពួកច្រាន់ និងចាម្ប៉ា បានទទួលស្គាល់នូវឧត្តមភាពរបស់ម៉ុងហ្គោល ។

## ៤.២. ចាម្ប៉ា

កំឡុងសម័យនោះផងដែរ ពួកស្ដេចច្រាន់បានធ្វើសង្គ្រាមប្រឆាំងនឹងនគរ**ចាម្ប៉ា** នៅភាគខាងត្បូង ការបន្តនូវប្រវត្តិសាស្ត្រដ៏វែងឆ្ងាយ នៃការពង្រីកទឹកដីខាងត្បូងរបស់ពួកវៀត (បានស្គាល់ថាជា ណាម ធាន = Nam Tiến) ដែលបានចាប់ផ្ដើមបន្តិចៗម្ដងបន្ទាប់ ពីការទទួលបានឯករាជ្យពីចិនវិញ ។ ជារឿយ ពួកគេបានប្រទះនឹងការតស៊ូខ្លាំងក្លាពីពួកចាម ។ កងទ័ពចាម្ប៉ាដឹកនាំដោយស្ដេច**ស្រី បុប្ផា** (ចាម:Po Binasuor រឺ Che Bonguar) បានសម្លាប់ស្ដេច **ច្រាន់ ឌឺ តុង** (Trần Duệ Tông) ក្នុងសមរភូមិប្រយុទ្ធ និងថែមទាំងតាំងបន្ទាយ នៅរាជធានី **ដាយ វៀត ថាង ឡុង** ក្នុងឆ្នាំ១៣៧៧ គ.ស. និងម្ដងទៀតនៅឆ្នាំ១៣៨៣ គ.ស. ។ ក៏ប៉ុន្តែ រាជវង្សច្រាន់ក៏ទទួលជោគជ័យដែរ ក្នុងការទទួលបានខេត្តចាម្ប៉ាពីរ ដែលស្ថិតនៅក្បែរ **ហួ** (Huế) សព្វថ្ងៃនេះ តាមរយៈការបង្កប់ន័យសន្តិភាពនៃការអភិសេកតាមបែបនយោបាយនៃព្រះនាង **ហ៊ុយយិន ច្រាន់** (Huyền Trân) ទៅឲស្ដេចចាម ។

## ៤.៣. ការកាន់កាប់របស់មិងនិងការងើបឡើងនៃរាជវង្សឡេ

រាជវង្សច្រាន់ដល់ពេលដួលរំលំដោយមន្ត្រីវាំងម្នាក់នៃរាជវង្ស **ហូ គុយ លី** (Hồ Quý Ly) ។ ហូ គុយ លី បានបង្ខំស្ដេចច្រាន់ចុងក្រោយឲដាក់រាជ្យ ហើងនិងបានដណ្ដើមរាជ្យបល្ល័ង្កទៀតក្នុងឆ្នាំ១៤០០ ។ លោកក៏បានផ្លាស់ប្ដូរឈ្មោះប្រទេសទៅជា **ដាយ ង្វ** (Đại Ngu) (Hán tự: 大虞) និងប្ដូររាជធានីទៅ **តាយ ដុ** (Tây Đô) រាជធានីខាង **លិច ថាញ់ ហូវ** (Thanh Hóa) ។ ថាង ឡុង ត្រូវបានដាក់ឈ្មោះសារជាថ្មីថា **ដុង ដុ** (Đông Đô) រាជធានីខាងកើត។ ទោះបីជាត្រូវបានគេស្ដីបន្ទោសយ៉ាងធំធេងចំពោះការបង្កឲគ្មានសាមគ្គីភាពជាតិ ហើយនិងក្រោយមកបង់ខាតប្រទេសទៅឲ**រាជវង្សមិង**ចិនក៏ដោយ ក៏រជ្ជកាលរបស់ ហូ គុយ លី បានបញ្ចូលនូវកំណែទម្រង់ដ៏ជឿនលឿនធំធេងឲស្ដែងឡើងជាច្រើន រួមមាន ការបន្ថែមលេខនពន្ធដើម្បីការប្រលងថ្នាក់ជាតិខ្លះៗ ការទិះគៀនដោយចំហចំពោះទស្សនវិជ្ជា**ខុងជឺ** ការប្រើប្រាស់ក្រដាសរូបបិយបណ្ណជំនួសកាក់ ការបណ្ដាក់ទុនក្នុងការសាងសង់សំពៅចម្បាំងធំៗ និងកាំភ្លើងធំ ហើយនិងកំណែទម្រង់ដីធ្លីជាដើម ។ ទ្រង់បានផ្ទេររាជ្យបល្ល័ង្កទៅឲបុត្រារបស់ព្រះអង្គ **ហូ ហាន ធឿង** (Hồ Hán Thương) ក្នុងឆ្នាំ ១៤០១ និងបានសន្មតគោរម្យងារថា ថាយ **ធឿង វ៉ាង** (Thái Thượng Hoàng) ដែលលក្ខណៈស្រដៀង នឹងពួកស្ដេចច្រាន់ដែរ ។

ក្នុងឆ្នាំ១៤០៧ ក្រោមលេសដើម្បីជួយស្ដាររាជវង្សច្រាន់ឡើងវិញ កងទ័ព**មិង**ចិនបានធ្វើការឈ្លានពាន ដាយ ង្វ និងចាប់ខ្លួន **ហូ គុយ លី** និង**ហូ ហាន ធឿង** ។ **រាជវង្សហូ** បានមកដល់ទីបញ្ចប់បន្ទាប់ពីកាន់អំនាចបានត្រឹមតែ ៧ឆ្នាំប៉ុណ្ណោះ ។ ពួកទ័ពដែលកាន់កាប់ដោយមិងបានបញ្ចូល ដាយ ង្វ ចូលទៅក្នុងចក្រភពមិង បន្ទាប់ពីបានអះអាងថាគ្មានរាជទាយាទរាជបល្ល័ង្កស្ដេចច្រាន់ទេ ។ ភ្លាមៗនោះដែរ ស្ទើរតែទាំងអស់នៃ អ្នករាជានិយមច្រាន់បានចាប់ផ្ដើម

ធ្វើសង្គ្រាមតស៊ូ ។ ការតស៊ូ ក្រោមការដឹកនាំរបស់**ច្រាន់ គុយ** (Trần Quĩ) នៅលើកដំបូងបានទទួលភាពជឿនលឿនខ្លះដែរ ក៏ប៉ុន្តែនៅពេលដែល **ច្រាន់ គុយ** បានប្រហារជីវិត មេទ័ពធំៗកំពូលពីរនាក់ ធ្វើឲ្យអស់ក្តីសង្ឃឹម ការប្រេះឆាក៏បានរីកធំៗឡើងក្នុងតំនែងរបស់គាត់ និងធ្វើឲ្យជាលទ្ធផលនៃការបរាជ័យនៅឆ្នាំ ១៤១៣ ។

ក្នុងឆ្នាំ១៤១៨ កសិករដ៏ស្តុកស្តម្ភម្នាក់ **ឡេ ឡយ** (Lê Lợi) បានដឹកនាំការបះបោរនូវ **ឡាម សឺន** (Lam Sơn) ប្រឆាំងនឹងពួកមិងពីមូលដ្ឋានទ័ពរបស់គាត់នៅ **ឡាម សឺន** (ខេត្ត ថាញ់ ហ៊ា = Thanh Hóa) ។ ដោយជំនះលើដំណើរថយក្រោយនៅពេលដំបូងខ្លះ ហើយនិងការប្រឹក្សាយុទ្ធសាស្រ្តពី **ង្វៀន ត្រៃ** (Nguyễn Trãi) ចលនារបស់ **ឡេ ឡយ** ជាចុងក្រោយប្រមូលបានភិមសា ហើយចល័តឆ្ពោះទៅខាងជើង និងចាប់ផ្តើមសង់បន្ទាយមួយនៅ **ដុង ខ្វាន** (Đông Quan) (ឥឡូវហានណូយ) រាជធានីគ្រប់គ្រងដោយពួកមិង ។ ព្រះចៅអធិរាជមិងបានបញ្ជូនកងទ័ពជំនួយ ក៏ប៉ុន្តែ **ឡេ ឡយ** បានធ្វើការវាយឆ្មក់និងសម្លាប់មេទ័ពបញ្ជាការមិង **លាវ ថាង** (Liễu Thăng, ចិន:Liu Sheng = លាវ សឹង) នៅ **ឈី ឡាង** (Chi Lăng) ។ កងទ័ពមិងនៅឯ **ដុង ខ្វាន** (Đông Quan) បានសុំចុះចាញ់ ។ ការបះបោរ ឡាម សឺន បានសម្លាប់ទាហានមិង៣០០,០០០នាក់ ។ ក្នុងឆ្នាំ១៤២៨ ឡេ ឡយ បានស្នងរាជ្យ ហើយបានចាប់ផ្តើម **រាជវង្ស ហាវ ឡេ** (Hậu Lê) (ឡេមុន រឺ ចុងក្រោយ) ។ **ឡេ ឡយ** បានដាក់ឈ្មោះប្រទេសឡើងវិញថា **ដាយ វៀត** (Đại Việt) ដូចមុន និងប្តូររាជធានី ទៅ **ថាង ឡុង** (Thăng Long) វិញ ។

រាជវង្សឡេ បានបន្តកំណែទម្រង់ដីធ្លី ដើម្បីសេដ្ឋកិច្ចរស់ឡើងបន្ទាប់ពីសង្គ្រាម ។ មិនដូចពួកស្តេចលី និងច្រាន់ទេ ដែលរងឥទ្ធិពលពីពុទ្ធសាសនា ក្រុមស្តេចឡេទោរទន់ទៅរក**លទ្ធិខុងជឺ** ។ ការចែងច្បាប់ដែលអាចយល់បានមួយ ច្បាប់ **ហុង ឌុក** (Hồng Đức) ត្រូវបានដាក់បញ្ចូលជាមួយធាតុរបស់ខុងជឺដ៏តឹងរឹងខ្លះ ក៏ប៉ុន្តែក៏រួមមានដែរ ច្បាប់ដែលបានវិវត្ត ដូចជាសិទ្ធិស្រ្តី ។ សិល្បៈ និងស្ថាបត្យកម្មកំឡុងរាជវង្សឡេក៏រងឥទ្ធិពលខ្លាំងដោយរចនាបថចិនជាងនៅសម័យរាជវង្សលី និងច្រាន់ ។ រាជវង្សឡេ បានដាក់ឲ្យប្រើគំនូរផែនទីប្រទេស ហើយដែលមាន **ង៉ោ ស៊ី លាន** (Ngô Sĩ Liên) បន្តកិច្ចការនិពន្ធប្រវត្តិសាស្រ្ត ដាយ វៀតរហូតដល់សម័យស្តេច **ឡេ ឡយ** ។ ស្តេច **ឡេ ថាញ់ តុង** (Lê Thánh Tông) បានបើកសម្ភោធមន្ទីរពេទ្យជាច្រើន ដែលមានមន្រ្តីៗ ចែកចាយថ្នាំសង្កូវជាច្រើនទៅតំបន់មួយចំនួន ដែលរងការប៉ះពាល់ជាមួយ ជំងឺឆ្លងរាតត្បាត។

ឆ្នាំ១៤៧១ កងទ័ពឡេដឹកនាំដោយស្តេច **ឡេ ថាញ់ តុង** (Lê Thánh Tông) បានចូលលុកលុយចាម្ប៉ាជាការឈ្លានពានរបស់វៀតណាមនៅចាម្ប៉ាឆ្នាំ១៤៧១ និងកាន់កាប់បានរាជធានីចាម វិជ័យ ។ ព្រឹត្តិការណ៍នេះ បានបញ្ចប់ឥទ្ធិពលចាម្ប៉ាដែលជានគរមានអំនាច ទោះបីជានគរចាម ដែលនៅសល់តូចៗនៅតែបន្តអស់រយៈពេលពីរបីសតវត្សទៀតក៏ដោយ ។ វាជាដើមហេតុ នូវការរប៉ាត់រប៉ាយបែកខ្ញែកប្រជាជនចាមទូទាំងអាស៊ីអាគ្នេយ៍ ។ ដោយនគរចាម្ប៉ាបានខូចខ្ទីភាគច្រើនហើយ និងប្រជាជនចាមបានត្រូវនិរទេសបំបង់ រឺ ត្រូវសង្កត់សង្កិន ការដាក់អាណានិគមរបស់វៀតណាម នូវអ្វីដែលឥលូវជាភាគកណ្តាលនៃប្រទេសវៀតណាមបានបណ្តាលឲ្យគ្មានការតស៊ូណារឹងមាំទៀតឡើយ ។ ក៏ប៉ុន្តែ ការឃាយីព្យាបាទបានកើនឡើងយ៉ាងខ្លាំងដោយអ្នកតាំងលំនៅថ្មី **គិញ** (Kinh) (វៀត) ហើយនិងការធ្វើសមាហរណកម្មនៃដែនដីចាមដើមទៅជាជាតិវៀតណាម ភាគច្រើននៃប្រជាជនចាមថ្វីត្បិតនៅមានក្នុងប្រទេសវៀតណាម ហើយនិងឥលូវពួកគេបានចាត់ទុកថាជាជនជាតិមួយ ក្នុងចំណោមជនជាតិភាគតិចដ៏សំខាន់ៗនៅក្នុងប្រទេសវៀតណាមសម័យទំនើបនេះ ។ ទីក្រុង **ហ៊ូ** បានស្ថាបនិក ក្នុងឆ្នាំ១៦០០តាំងនៅក្បែរៗជិតនឹងរាជធានីចាម្ប៉ានៃ ឥន្ទ្របុរៈ ដែលស្ថិតនៅទីនោះយូរហើយ ។ ឆ្នាំ១៤៧៩ ស្តេច **ឡេ ថាញ់ តុង** (Lê Thánh Tông) ក៏បានធ្វើ

យុទ្ធនាការតទល់នឹង ប្រទេសឡាវដែរ ហើយបានកាន់កាប់រាជធានី **ហ្លួងព្រះបាង** ។ ទ្រង់បានធ្វើការលុកលុយបន្ថែមឆ្ពោះទៅខាងត្បូងទៅ ក្នុងតំបន់ទន្លេអីរ៉ាវ៉ាឌី ប្រទេសភូមាសព្វថ្ងៃនេះ មុនពេលដកទ័ពថយមកវិញ ។




ផែនទីវៀតណាមបង្ហាញការសញ្ជ័យ នៅភាគខាងត្បូង ( *ណាម ធាន = Nam tiến ១០៦៩-១៧៥៧*) ។ ទឹកក្រូច: មុនសតវត្សទី១១ ។ លឿង: សតវត្សទី១១ ។ បៃតងខ្ចី: សតវត្សទី១៥ ។ បៃតងចាស់: សតវត្សទី១៦ ។ ក្រាវ: សតវត្សទី១៨ ។ ឡាយ ឆៅ (Lai Chau) និងដៀន បៀន (Dien Bien) (ខាងជើងឈៀងខាងលិច): សតវត្សទី១៩ ។

## ៥. សម័យបែងចែក (១៥២៨-១៨០២)

### ៥.១. សង្គ្រាមផ្ទៃក្នុងឡេ និងម៉ាក់

រាជវង្សឡេ ត្រូវបានផ្តួលរំលំដោយមេទ័ពរបស់ខ្លួន នាម **ម៉ាក់ ដាង ឌុង** (Mạc Đăng Dung) ក្នុងឆ្នាំ ១៥២៧។ លោកបានសម្លាប់ព្រះចៅអធិរាជឡេ ហើយប្រកាសខ្លួនឯងថាជាព្រះចៅអធិរាជ ដោយចាប់ផ្តើមនូវរាជវង្សម៉ាក់ (Mạc) ។ បន្ទាប់ពីការកម្ចាត់ការបះបោរជាច្រើនអស់រយះពេលពីរឆ្នាំ **ម៉ាក់ ដាង ឌុង** បានអនុវត្តតាមរាជវង្សច្រាន់ និងបានផ្ទេររាជ្យសម្បត្តិទៅឲកូនប្រុសលោក **ម៉ាក់ ដាង ដូញ** (Mạc Đăng Doanh) ហើយបានក្លាយជា **ថាយ ធឿង ហ៊ាំង** (Thái Thượng Hoàng) ។

ខណៈនោះដែរ **ង្វៀន គីម** (Nguyễn Kim) អតីតមន្ត្រីក្នុងរាជវាំងឡេបានបះបោរប្រឆាំងនឹងពួកម៉ាក់និងជួយស្តេច **ឡេ ច្រាង តុង** (Lê Trang Tông) ស្តាររាជវាំងឡេឡើងនៅតំបន់ **ថាញ់ ហ៊ា** (Thanh Hóa) ។ នេះជាហេតុដែលសង្គ្រាមក្នុងស្រុកបានចាប់ផ្តើមរវាងហ្លួងខាងជើង (ម៉ាក់) និងហ្លួងខាងត្បូង (ស្តារឡេ) ។ **ខាង ង្វៀន គីម** បានគ្រប់គ្រងប៉ែកខាងត្បូងនៃ **ដាយ វៀត** (ពី ថាញ់ហ៊ា = Thanhhoa មកខាងត្បូង ) ទុកភាគខាងជើង (រួមមាន ដុង

គីញ-ហានណូយ ) ស្ថិតក្រោមការគ្រប់គ្រងរបស់ម៉ាក់ ។ នៅពេលដែល **ង្វៀន គីម** ត្រូវបានគេលួចធ្វើឃាតក្នុងឆ្នាំ ១៥៤៥ អំនាចកងទ័ពបានធ្លាក់ចូលក្នុងកណ្តាប់ដៃកូនប្រសាររបស់លោក **ទ្រិញ គៀម** (Trịnh Kiểm) ។ ឆ្នាំ១៥៥៨ កូនប្រុសរបស់ ង្វៀន គីម **ង្វៀន ហួង** (Nguyễn Hoàn) ដោយសង្ស័យថា **ទ្រិញ គៀម**បានសំលាប់ ឪពុក ពេលនោះ គេក៏បានសុំអំនាចពីបងប្អូនរបស់គេ៩ដោយភិតភ័យ បានសុំធ្វើជាចៅហ្វាយស្រុកខេត្តខាងត្បូងដ៏ឆ្ងាយក្បែរៗ**ខាង ប៊ិញ** (Quảng Bình) មកទល់ **ប៊ិញ ឌិញ** (Bình Định) សព្វថ្ងៃនេះ ។ ហួង បានធ្វើពុតជាវង្វេង ដូច្នេះ **គៀម** ត្រូវបានគេបញ្ឆោតដោយគិតថាបញ្ជូនហួងទៅភាគខាងត្បូងវាជាការល្អ ពេលនោះហួងនឹងត្រូវស្លាប់យ៉ាងលឿន នៅតំបន់ព្រំដែនដែលគ្មានច្បាប់ទម្លាប់ ។ យ៉ាងណាក៏ដោយ **ហួង** បានគ្រប់គ្រងភាគខាងត្បូងយ៉ាងប៉ិនប្រសប់ ខណៈពេលដែល ទ្រិញ គៀម និងកូនប្រុសរបស់គេបានបន្តធ្វើសង្គ្រាមតទល់នឹងពួកម៉ាក់ ។ **ង្វៀន ហួង** បានបញ្ជូនប្រាក់កាស និងពួកទាហានទៅភាគខាងជើងដើម្បីជួយ ក្នុងសង្គ្រាមប៉ុន្តែគេបន្តិចៗម្តងកាន់តែឯករាជ្យឡើងៗ ដោយប្រែក្លាយធនធានសេដ្ឋកិច្ច របស់អាណាចក្ររបស់ពួកគេទៅជាគោលដៅដោះដូរពាណិជ្ជកម្មអន្តរជាតិទៅវិញ។

សង្គ្រាមក្នុងស្រុករវាង រាជវង្សឡេ/ទ្រិញ និងម៉ាក់បានបញ្ចប់ក្នុងឆ្នាំ១៥៩២ នៅពេលដែលកងទ័ព **ទ្រិញ ទុង** (Trịnh Tùng) បានសញ្ជ័យបាន**ហានណូយ** និងប្រហារជីវិតស្តេច **ម៉ាក់ ម៉ៅ ហុប** (Mạc Mậu Hợp) ។ អ្នករស់រាននៃព្រះញាតិវង្សម៉ាកបានភៀសខ្លួនទៅ កាន់ភ្នំភាគខាងជើងក្នុងខេត្ត **កាវ បាង** (Cao Bằng) និងបន្តគ្រប់គ្រងនៅទីនោះទៀតរហូតដល់ឆ្នាំ១៦៦៧នៅពេលនោះ **ទ្រិញ តាក់** (Trịnh Tạc) បានធ្វើសញ្ជ័យយកបានដែនដីម៉ាក់ចុងក្រោយមួយនេះទៀត ។ ពួកស្តេចឡេ តាំងតែពីការស្តារមកវិញរបស់ **ង្វៀន គីម** ដើរតួត្រឹមតែជានាមប៉ុណ្ណោះ ។ បន្ទាប់ពីធ្លាក់រាជវង្សម៉ាក់ អំនាចពិតទាំងអស់នៅភាគជើងជារបស់ពួកលោកម្ចាស់ទ្រិញ (Trịnh) ។

## ៥.២. <u>សង្គ្រាមទ្រិញ-ង្វៀន</u>

ក្នុងឆ្នាំ១៦០០ **ង្វៀន ហួង** ក៏បានប្រកាសខ្លួនថាជាលោកម្ចាស់ (ជាផ្លូវការ *វឿង* = Vương, និយមហៅថា *ជួ* = Chúa = ខ្មែរៈហៅថា ចៅ) និងបានបដិសេដបញ្ជូនមាសប្រាក់ និងកងទ័ពបន្ថែមទៀតជួយដល់ពួកទ្រិញ ។ លោកក៏បានផ្លាស់រាជធានីទៅ ភូ សួន (Phú Xuân) សម័យបច្ចុប្បន្ន ហ៊ូ (Huế) ។ **ង្វៀន ហួង**បានទទួលមរណៈនៅឆ្នាំ ១៦១៣ បន្ទាប់ពីគ្រប់គ្រងភាគខាងត្បូងអស់រយៈពេល៥៥ឆ្នាំមក ។ លោកត្រូវបានបន្តវេនដោយកូនប្រុសទី៦របស់លោក **ង្វៀន ផាក់ ង្វៀន** (Nguyễn Phúc Nguyên) ដែលជាអ្នកដូចគ្នាបដិសេធទទួលស្គាល់នូវអំនាចរបស់ពួកទ្រិញ ប៉ុន្តែនៅតែសច្ចាស្មោះស្ម័គ្រចំពោះស្តេចឡេ ។

**ទ្រិញ ត្រាង** (Trịnh Tráng) បានបន្តវេន **ទ្រិញ តុង** (Trịnh Tùng) ឪពុកគាត់ រហូតដល់មរណភាពរបស់គាត់ក្នុងឆ្នាំ១៦២៣ ។ លោកត្រាងបានបញ្ជា៩ **ង្វៀន ផាក់ ង្វៀន**ប្រគល់អំនាច៩គាត់ ។ បញ្ជាត្រូវបានបដិសេធទាំងពីរលើក ។ ឆ្នាំ១៦២៧ **ទ្រិញ ត្រាង** បានបញ្ជូនកងទ័ព១៥០,០០០នាក់ ទៅភាគខាងត្បូងក្នុងយុទ្ធនាការសឹកបរាជ័យមួយ ។ ពួកទ្រិញ កាន់តែខ្លាំងរឹងមាំឡើង ដោយមានប្រជាជន សេដ្ឋកិច្ច និងកងទ័ពកាន់តែច្រើន ប៉ុន្តែពួកគេមិនអាចផ្ចាញ់ពួកង្វៀនបានទេ ដោយពួកគេបានសាងកំផែងថ្មការពារពីរផ្ទាំង និងបានបណ្តាក់ទុនលើកាំភ្លើងធំរបស់ប៉័ទុយហ្កាល់ ។

មួយក្នុង ចំណោមផែនទី បស្ចឹមប្រទេសដំបូងគេបង្អស់ អំពីប្រទេសវៀតណាមបោះពុម្ព ក្នុងឆ្នាំ១៦៥១ ដោយ **អេឡិចសង់ដ្រេ ដឺ រ៉ូដ** (Alexandre de Rhodes) (ទិសខាងជើងត្រូវបានដៅទិស នៅខាងស្ដាំ) ។




ផែនទីវៀតណាមបង្ហាញ (ប្រហែល) តំបន់មួយចំនួនបានកាន់កាប់ ដោយពួកទ្រិញ ង្វៀន ម៉ាក់ និងចាម្ប៉ាប្រហែលឆ្នាំ១៦៤០ ។ ពណ៌ត្នោតៈដែនដីទ្រិញ។ លឿងៈដែនដីង្វៀន ។ បៃតងៈចាម្ប៉ា (ស្ថិតក្រោមអតីតភាពលោកម្ចាស់ង្វៀន) ។ ផ្កាឈូក (កាវបាង = Cao Bang)ៈដែនដីម៉ាក់ ។

**សង្គ្រាមទ្រិញ-ង្វៀន**បានបន្តពី១៦២៧ដល់១៦៧២ ។ កងទ័ពទ្រិញបានធ្វើការវាយលុកយ៉ាងហោចណាស់ប្រាំពីរលើក សុទ្ធតែបរាជ័យទាំងអស់ ដើម្បីចាប់យក **ភូ សួន** (Phú Xuân) ។ ម្ដងនោះ ផ្ដើមឡើងក្នុងឆ្នាំ១៦៥១ ពួកង្វៀនខ្លួនឯងបានបន្តការវាយលុក និងបានវាយប្រហារលើផ្នែកមួយចំនួននៃដែនដីទ្រិញ ។ យ៉ាងណាក៏ដោយពួកទ្រិញក្រោមការដឹកនាំមេដឹកនាំថ្មី **ទ្រិញ តាក់** (Trịnh Tạc) បានបង្ខំឲពួកង្វៀនត្រលប់ទៅវិញនៅឆ្នាំ១៦៥៥ ។ បន្ទាប់ពីការវាយលុកលើកចុងក្រោយមួយមកក្នុងឆ្នាំ១៦៧២ ទ្រិញ តាក់បានយល់ព្រមនឹងការផ្អាកសង្គ្រាមជាមួយលោកម្ចាស់ង្វៀន **ង្វៀន ផាក់ តាន** (Nguyễn Phúc Tần) ។ ប្រទេសក៏ត្រូវបែងចែកជាពីរយ៉ាងពិតមែន ។

## ៥.៣. <u>ការពង្រីកទឹកដីមកភាគខាងត្បូង</u>

ពួកទ្រិញ និងង្វៀនបានថែរក្សាសន្តិភាពជាបងប្អូនសំរាប់រយៈពេលរាប់រយឆ្នាំបន្ទាប់មកទៀត កំឡុងសម័យនោះភាគីទាំងពីរបានបង្កើតនូវសមិទ្ធិផលសំខាន់ៗជាច្រើន ។ ពួកទ្រិញបានបង្កើតការិយាល័យរាជការកណ្ដាលទទួលបន្ទុកថវិការរដ្ឋ និងផលិតរូបិយវត្ថុ បង្រួមអង្គភាពធំៗជាច្រើនទៅជាប្រព័ន្ធទសភាគបង្កើតរោងបោះពុម្ព ដើម្បីកាត់បន្ថយតំរូវការសម្ភារៈបោះពុម្ពសំខាន់ៗពីប្រទេសចិន បើកសម្ភោធបណ្ឌិត្យសភាយោធា និងចងក្រងសៀវភៅប្រវត្តិសាស្ត្រ ។




មួយក្នុង ចំណោមផែនទី បស្ចឹមប្រទេសដំបូងគេបង្អស់ អំពីប្រទេសវៀតណាមបោះពុម្ពក្នុងឆ្នាំ១៦៥១ ដោយអេឡិចសង់ដ្រេ ដឺ រ៉ូដ (Alexandre de Rhodes) (ទិសខាងជើងត្រូវបានដៅទិស នៅខាងស្ដាំ) ។

ខណៈពេលនោះដែរ ពួកលោកម្ចាស់ង្វៀនបានបន្តការពង្រីកទឹកដីទៅភាគខាងត្បូងដោយការធ្វើសញ្ជ័យលើទឹកដី**ចាម**ដែលនៅសេសសល់ ។ និគមជនវៀតក៏បានមកដល់ដែរ តំបន់ដែលមានប្រជាជននៅរប៉ាត់រប៉ាយ ដែលគេស្គាល់ថាជា*ចេនឡាទឹកលិច*គឺជាផ្នែកមួយ នៃដីសណ្ដមេគង្គក្រោមនៃចេនឡា (សព្វថ្ងៃកម្ពុជា) ។ នៅចន្លោះពាក់កណ្ដាលសតវត្សទី១៧ដល់ពាក់កណ្ដាលសតវត្សទី១៨ ពេលនោះ**ចេនឡា** បានចុះខ្សោយដោយសារវិវាទ និងការលុកលុយរបស់សៀម ពួកលោកម្ចាស់ង្វៀនបានប្រើវិធីផ្សេងៗ នយោបាយអភិសេក

ការដាក់សម្ពាធការទូត ការគាំទ្រខាងនយោបាយ និងកងទ័ព ដើម្បីទទួលបានតំបន់ដែលនៅជុំវិញសៃហ្គន និងដីសណ្ដទន្លេមេគង្គសព្វថ្ងៃនេះ ។ កងទ័ពង្វៀនជាច្រើនដងក៏បានទង្គិចគ្នាផងដែរ ជាមួយកងទ័ព**សៀម**ដើម្បីបង្កើតឥទ្ធិពលលើចេនឡា ។

## ៥.៤. កាលបះបោរនិងរាជវង្ស តៃ សឺន

ក្នុងឆ្នាំ១៧៧១ ការបះបោរ **តៃ សឺន** បានបែកធ្លាយឡើងនៅ **គុយ ញ៉ុន** (Quy Nhơn) ដែលស្ថិតក្រោមការដឹកនាំនៃត្រកូលង្វៀន ។ ក្រុមមេដឹកនាំនៃការបះបោរនេះគឺជាបងប្អូនបីនាក់ដែលមានឈ្មោះថា **ង្វៀន ញ៉ាក់** (Nguyễn Nhạc), **ង្វៀន លូ** (Nguyễn Lữ) និង **ង្វៀន ហ៊ូ** មិនជាប់សាច់ឈាមនឹងពួកលោកម្ចាស់ង្វៀនទេ ។ នៅឆ្នាំ១៧៧៦ ពួក **តៃ សឺន** បានកាន់កាប់ទឹកដីលោកម្ចាស់ង្វៀនទាំងអស់ និងសម្លាប់ស្ទើរតែគ្មានសល់នូវក្រុមគ្រួសាររាជវង្ស ។ ព្រះអង្គម្ចាស់មួយអស់នៅមានព្រះជន្មនៅឡើយ **ង្វៀន ផាក់ អាញ់** (Nguyễn Phúc Ánh) (ជារឿយៗហៅថា **ង្វៀន អាញ់** = Nguyễn Ánh ) បានភៀសព្រះកាយទៅដល់សៀម ហើយបានទទួលបានការគាំទ្រខាងកងទ័ពពីស្ដេចសៀម ។ **ង្វៀន អាញ់** បានត្រលប់មកវិញជាមួយកងទ័ពសៀម៥០០០០នាក់ ដើម្បីដណ្ដើមអំណាចមកវិញក៏ប៉ុន្តែត្រូវបរាជ័យនៅសមរភូមិ **៉រាច់ កាម-ស៊យ មុត** (Rạch Gầm–Xoài Mút)និងត្រូវគេសម្លាប់ស្ទើរតែទាំងអស់ ។ ង្វៀន អាញ់ បានភៀសខ្លួនពីវៀតណាម ក៏ប៉ុន្តែទ្រង់មិនបានបោះបង់ចោលឡើយ ។



ទុក្ករបុគ្គលកាតូលិកជាច្រើន (ពួកអ្នកមានជំនឿនិងពួកអាចារ្យ) បានថ្វាយជីវិតរបស់គេ ឲព្រះយេស៊ូនៅតុងកឹង កូសាំងស៊ីន និងអណ្ណាម កំឡុងពេលការធ្វើទុក្ខបុកម្នេញ។ ក្នុងឆ្នាំ១៩០០មានទុក្ករបុគ្គល៦៤នាក់ ដែលបានប្រទានពរពីអ្នក៥៤នាក់ជាអ្នកនៅជាមួយពួកគេ មានតែសង្គម នៃសន្តបុគ្គលដូមិនិក (Dominic) ប៉ុណ្ណោះបានថ្វាយទុក្ករបុគ្គល២៦នាក់ ។

កងទ័ព **តៃ សឺន** បានបញ្ជាដោយ **ង្វៀន ហ៊ូ** ចល័តទៅភាគជើងនៅឆ្នាំ១៧៨៦ ដើម្បីតទល់ប្រឆាំងនឹងលោកម្ចាស់ទ្រិញ **ទ្រិញ ខៃ** (Trịnh Khải)។ កងទ័ពទ្រិញបានបរាជ័យ ហើយនិង **ទ្រិញ ខៃ**បានធ្វើអត្តឃាត ។ កងទ័ព **តៃ សឺន** បានកាន់កាប់រាជធានីតិចជាងពីរខែ ។ ព្រះចៅអធិរាជឡេចុងក្រោយ **ឡេ ឆៀវ ថុង** (Lê Chiêu Thống)បានភៀសព្រះកាយទៅចិន ហើយបានដាក់សំនើទៅព្រះចៅអធិរាជឈិងចិនសុំជំនួយ ។ ព្រះចៅអធិរាជឈិង **ឆៀនឡុង** (Qianlong) បានផ្គត់ផ្គង់ដល់ **ឡេ ឆៀវ ថុង** ជាមួយនឹងកងទ័ពដ៏ច្រើនសន្ធឹកសន្ធាប់ប្រហែល២០០,០០០កងដើម្បីយករាជ្យបល្ល័ង្កមកវិញពីពួកអ្នកជ្រែករាជ្យ ។ **ង្វៀន ហ៊ូ** បានប្រកាសខ្លួនថាជាព្រះចៅអធិរាជ **ខ្វាង ទ្រុង** (Quang Trung) និងកម្ចាត់កងទ័ពឈិងជាមួយនឹងទាហាន១០០,០០០នាក់ ក្នុងយុទ្ធនាការ៧ថ្ងៃដ៏គួរឲភ្ញាក់ផ្អើលកំឡុងថ្ងៃចូលឆ្នាំថ្មី (តេត = Tết ) ។ កំឡុងរជ្ជកាលរបស់ព្រះអង្គ **ខ្វាង ទ្រុង** បានធ្វើឲលេចឡើងឃើញនូវកំនែទម្រង់ជាច្រើន ក៏ប៉ុន្តែបានសុគតដោយមិនដឹងមូលហេតុ នៅតាមផ្លូវយាងទៅភាគខាងត្បូងក្នុងឆ្នាំ១៧៩២ ក្នុងព្រះជន្ម៤០វស្សា ។

កំឡុងរជ្ជកាលអធិរាជ **ខ្វាង ទ្រុង**, ដាយ វៀត ជាការពិតទៅបានបែកជាបីអង្គភាពនយោបាយ ។ មេដឹកនាំ **តៃ សឺន ង្វៀន ញ៉ាក់** បានគ្រប់គ្រងភាគកណ្ដាលនៃប្រទេសចាប់ពី

រាជធានីរបស់លោក **គុយ ញ៉ុន** (Qui Nhơn) ។ ព្រះចៅអធិរាជ **ខ្វាង ទ្រុង** បានគ្រប់គ្រងភាគខាងជើងពីរាជធានី **ភូ សួន ហ៊ូ** (Phú Xuân Huế) ។ នៅភាគខាងត្បូង ង្វៀន អាញ់ បានជួយដោយកំណែនកងទ័ពឆ្នើមៗជាច្រើនពីភាគខាងត្បូង បានកាន់កាប់បាន **គៀ ឌិញ** (Gia Định) (សម័យបច្ចុប្បន្ន **សៃហ្គន**) ក្នុងឆ្នាំ១៧៨៨ និងបង្កើតបានជាមូលដ្ឋានដ៏រឹងមាំសំរាប់កងទ័ពទ្រង់ ។

បន្ទាក់ពីការចូលទីវង្គត់ ស្ដេច **ខ្វាង ទ្រុង**, **រាជវង្ស តៃ សឺន** ប្រែជារង្គោះរង្គើដោយហេតុបងប្អូន ដែលនៅសល់បានប្រយុទ្ធប្រឆាំងគ្នាទៅវិញទៅមក ហើយនិងប្រជាជនមានភក្តីភាពទៅនឹងបុត្រាតូចរបស់ **ង្វៀន ហ៊ូ** (Nguyễn Huệ) ។ **ង្វៀន អាញ់** (Nguyễn Ánh) បានចេញក្ដោងទៅខាងជើងក្នុងឆ្នាំ១៧៩៩ ដោយកាន់កាប់មូលដ្ឋានទ័ព តៃ សឺន **គុយ ញ៉ុន** (Qui Nhơn) ។ ក្នុងឆ្នាំ១៨០១ កងកម្លាំងរបស់ទ្រង់បានដណ្ដើមបាន **ភូ សួន** (Phú Xuân) រាជធានីនៃពួក **តៃ សឺន** ។ **ង្វៀន អាញ់**នៅទីបញ្ចប់បានឈ្នះសង្គ្រាមក្នុងឆនាំ១៨០២ នៅពេលនៅទ្រង់បានឡោមព័ទ្ធ **ថាង ឡុង** (ហានណូយ) និងបានប្រហារជីវិតបុត្រារបស់ **ង្វៀន ហ៊ូ**, **ង្វៀន ខ្វាង ទ័ន** រួមជាមួយមេទ័ពនិងមន្ត្រីរបស់ តៃ សឺន ជាច្រើន ។ ង្វៀន អាញ់ បានឡើងសោយរាជ្យនិងហៅខ្លួនឯងថាជាព្រះចៅអធិរាជ **គា ឡុង** ។ គា គឺសំដៅលើ **គា ឌិញ** (Gia Định) ឈ្មោះចាស់នៃសៃហ្គន **ឡុង**គឺសំដៅលើ **ថាង ឡុង** ឈ្មោះចាស់នៃហានណូយ ។ ហេតុនេះហើយ **គា ឡុង** បាននាំមកនូវការបង្រួបបង្រួមប្រទេស ។ **រាជវង្សង្វៀន**បានបន្តរហូតដល់ការដាក់រាជ្យរបស់ **បាវ ដាយ** (Bảo Đại)ក្នុងឆ្នាំ១៩៤៥ ។ ដោយចិនអស់ជាច្រើនសតវត្សមកហើយបានចាត់ទុកថា ដាយ វៀត ជា**អណ្ណាម** **គា ឡុង** បានសុំឲព្រះចៅអធិរាជឈីងចិនដាក់ឈ្មោះប្រទេសឡើងវិញ ពីអណ្ណាមទៅ**ណាមវៀត**វិញ ។ ដើម្បីការពារការភាន់ច្រឡំណាមួយនៃអាណាចក្ររបស់ គា ឡុងជាមួយនគរពីបុរាណរបស់ **ទ្រៀវ ដា** (Triệu Đà) ព្រះចៅអធិរាជចិនបានឆ្លាស់លំដាប់លំដោយនៃពាក្យពីរម៉ាត់ទៅជា **វៀត ណាម**វិញ ។ ដូច្នេះហើយឈ្មោះវៀតណាមត្រូវបានប្រើតាំងពីរជ្ជកាលព្រះចៅអធិរាជ **គា ឡុង** មក ។ ពួកអ្នកប្រវត្តិវិទូថ្មីៗនេះបានរកឃើញថាឈ្មោះនេះមាន ក្នុងសៀវភៅចាស់ៗជាច្រើនដែលពួកវៀតណាមចាត់ទុកប្រទេសពួកគេថា ជា**វៀតណាម** ។

សម័យកាលនៃការបែងចែករួមជាមួយសោកនាដកម្ម និងការវិវត្តខាងប្រវត្តិសាស្ត្រដែលជុនដាបជាច្រើនបានជំរុញឲកវីនិពន្ធមួយចំនួន និងបានបង្កើតជាលើកស្នាដៃជាកំណាព្យរបស់វៀតណាមខ្លះ ដូចជាកំណាព្យរឺរកថារឿងនិទាននៃ**នាងគាវ** (ទ្រុយយ៉ិន គាវ = Truyện Kiều) ដោយលោក **ង្វៀន ឌុ** (Nguyễn Du) ចំរៀងប្រពន្ធទាហាន (**ឈិញ ភូ ង៉ាម** = Chinh Phụ Ngâm) ដោយ **ដាង ប្រាន កុង** (Đặng Trần Côn) និង **ដួន ធី ដៀម** (Đoàn Thị Điểm) ហើយនិងសមូហកម្មតិះដៀលជាកំណាព្យស្នេហានិពន្ធដោយកវីស្រី **ហូ សួន ហឿង** (Hồ Xuân Hương) ។

## ៦. <u>សតវត្សទី១៩ និងអាណានិគមបារាំង</u>

ការផ្សព្វផ្សាយពួកភាគខាងលិចក្នុងប្រទេសវៀតណាម និងការផ្សព្វផ្សាយរបស់វៀតណាមទៅពួកអឺរ៉ុបបានចុះកាលបរិច្ឆេទត្រលប់ ក្រោយវិញទៅឆ្នាំ១៦៦ម.គ.រួមជាមួយ និងការមកដល់នៃពួកឈ្មួញមកពីចក្រភពរ៉ូមមកទល់នឹងឆ្នាំ១២៩២រួមមានដំនើរទស្សនកិច្ចរបស់លោក**ម៉ាខូ ប៉ូឡូ**ហើយនិងដើមសតវត្សទី១៦មានការមកដល់ នៃពួកប៉ទុយហ្កាល់និងពួកពាណិជ្ជករ និងសាសនទូតអឺរ៉ុបផ្សេងៗទៀត ។**អេឡិចសង់ដ្រេ ដឺ រ៉ូដស៍** (Alexandre de Rhodes) អាចារ្យយេស៊ូជាតិបារាំងម្នាក់ បានធ្វើកិច្ចការដើមដំបូងឡើយឲកាន់តែប្រសើរឡើងដោយពួកសាសនទូត



ទង់ជាតិអណ្ណាមក្រោមអាណានិគម ។

ប៉ទុយហ្កាល់ និងបានអភិវឌ្ឍអក្សររ៉ូម៉ាំងវៀតណាមខ្វឿក ង៉ូ (Quốc Ngữ) ក្នុង*ឌីស្យុងណារ្យូម អង់ណាមមីទីកាំ លូស៊ីតង់ណាម អេត ឡាតាំងណាំ* (Dictionarium Annamiticum Lusitanam et Latinum) នៅឆ្នាំ ១៦៥១។

រវាងឆ្នាំ១៦២៧និង១៧៧៥ ត្រកូលមានឥទ្ធិពលពីរបានបែងចែកប្រទេសៈពួកលោកម្ចាស់ង្វៀនបានគ្រប់គ្រងភាគខាងត្បូង និងពួកលោកម្ចាស់ទ្រិញគ្រប់គ្រងភាគខាងជើង ។ **សង្គ្រាមទ្រិញ-ង្វៀន**បានផ្តល់ឲពួកពាណិជ្ជករអឺរ៉ុម នូវឱកាសជាច្រើនដើម្បីគាំទ្រភាគីនីមួយៗជាមួយ និងអាវុធនិងបច្ចេកវិទ្យាពួកប៉ទុយហ្កាល់បានជួយដល់ពួកង្វៀននៅភាគខាងត្បូងខណៈពេលនោះពួកដាច់ ក៏ជួយពួកទ្រិញនៅខាងជើងដែរ ។

ក្នុងឆ្នាំ១៧៨៤ កំឡុងការប៉ះទង្គិចគ្នារវាង **ង្វៀន អាញ់** (Nguyễn Ánh) ទាយាទនៃពួកលោកម្ចាស់ង្វៀនដែលនៅរស់ និងរាជវង្ស **តៃ សឺន** សង្ឃរាជកាតូលិកជាតិបារាំង **ពីណោអុច ដឺ បេហាំង** (Pigneaux de Behaine) បានចេញសំពៅទៅបារាំងដើម្បីស្វែងរកកងទ័ពត្រលប់មករក ង្វៀន អាញ់វិញ ។ ក្នុងរាជវាំងនៃស្តេចល្វីទី១៦ ពីណោអុចបានចូលជាអាជ្ញារកណ្តាល**សន្និសញ្ញាវ៉ឺសៃខ្លី** (Versailles) មួយដែលសន្យាថាកងទ័ពបារាំងជួយក្នុងការបន្ទរបន្ថយឲសភាពការណ៍នៅវៀតណាមដូចដើមវិញ ។ **បដិវត្តន៍បារាំង**បានផ្ទុះឡើងហើយផែនការរបស់ពីណោអុចក៏មិនបានសម្រេចទៅ ។ ដោយមិនចុះញ៉ម ពីណោអុច បានធ្វើដំណើរទៅដែនដី**ពូឌូឆឺរី**បារាំង (Puducherry) នៅឥណ្ឌា ។ លោកបានក៏ប៉ាល់ពីរគ្រឿង កងវរសេនាធំឥណ្ឌាមួយកង និងពោរពេញដោយពួកអ្នកស្ម័គ្រចិត្ត ហើយបានត្រលប់ទៅវៀតណាមវិញក្នុងឆ្នាំ១៧៨៨ ។ ម្នាក់ក្នុងចំណោមអ្នកស្ម័គ្រចិត្តរបស់ពីណោអុច **ហ្សង់-ម៉ារី ដាយ៉ូត** (Jean-Marie Dayot) បានរៀបចំកងទ័ពជើងទឹក ង្វៀន អាញ់ ឡើងវិញចូលរួមជាមួយជួរកងទ័ពអឺរ៉ុបហើយបានកម្ចាត់ពួក **តៃ សឺន នៅឃ្វី ញ៉ន** (Qui Nhơn)ក្នុងឆ្នាំ១៧៩២ ។ ពីរបីឆ្នាំក្រោយមក កងទ័ពរបស់ង្វៀន អាញ់ បានកាន់កាប់ សៃហ្គន ជាកន្លែងដែលលោកពីណោអុចបានទទួលមរណភាពក្នុងឆ្នាំ១៧៩៩ ។ អ្នកស្ម័គ្រចិត្តម្នាក់ទៀត **វិចទ័រ អូលីវៀរ ដឺ ពុយម៉ាណេល** (Victor Olivier de Puymanel)អាចនឹងសាងសង់បន្ទាយ **គា ឌិញ** (Gia Định)នៅភាគកណ្តាលសៃហ្គន ។

បន្ទាប់ពី**ង្វៀន អាញ់** បង្កើតឡើងនូវរាជវង្សង្វៀនក្នុងឆ្នាំ១៨០២ ទ្រង់បានប្រោសប្រណីដល់សាសនាកាតូលិក និងបានប្រើប្រាស់ជនជាតិអឺរ៉ុបខ្លះក្នុងរាជវាំងជាទីប្រឹក្សា ។ ក៏ប៉ុន្តែ ព្រះអង្គនិងអ្នកស្នងរាជ្យរបស់ព្រះអង្គគឺជាពួកខុងជឺអភិរក្សនិយម ដែលតស៊ូនឹងបស្ចឹមោបនីយកម្ម ។ ព្រះចៅអធិរាជង្វៀនក្រោយៗមកទៀត **មិញ ម៉ាង**, **ធាវ ទ្រី** (Thiệu Trị) និង **ទូ ដុក** (Tự Đức)បានសង្កត់សង្កិនយ៉ាងសាហាវឃោរឃៅលើសាសនាកាតូលិក និងបន្តនយោបាយ'បិទទ្វារ' ដោយការឃ្លាំមើលលើពួកបស្ចឹមលោកតាមការគំរាមកំហែង ដោយបន្តបន្ទាប់ដោយព្រឹត្តិការណ៍ជាច្រើនដូចជាការបះបោររបស់ **ឡេ វ៉ាន់ ខូយ** (Lê Văn Khôi)នៅពេលសាសនទូតជាតិបារាំង **ចូសិផ្វ ម៉ាឆង់ដ៍** (Joseph Marchand) បានលើកទឹកចិត្តដល់ពួកកាតូលិក ក្នុងស្រុកបះបោរក្នុងបំណងលើកព្រះចៅអធិរាជកាតូលិកមួយអង្គ ឲឡើងសោយរាជ្យ ។ រាប់សិបពាន់នាក់នៃជនជាតិវៀតណាម និងគ្រិស្តសាសនានិកកើតក្រៅប្រទេសត្រូវបានធ្វើទុក្ខបុកម្នេញ ហើយការដោះដូរពាណិជ្ជកម្ម ជាមួយពួកបស្ចឹមប្រទេសបានបង្អង់យឺតៗក្នុងរយៈកាលនេះ ។ មានការបះបោរជាញឹកញយប្រឆាំងនឹងពួកង្វៀន ដែលមានរាប់រយនៃព្រឹត្តិការណ៍ដូចៗគ្នា បានបន្តកត់ទុកក្នុង

កាលប្បវត្តិជាច្រើន ។ អំពើទាំងនេះកំពុងត្រូវបានប្រើជាលេសសំរាប់បារាំងចូលលុកលុយវៀតណាម ។ នៅដើមរាជវង្សង្វៀនបានភ្ជាប់សកម្មភាពស្ថាបនាជាច្រើននៃបុព្វការីជនមុនៗរបស់រាជវង្ស ធ្វើផ្លូវ ជីកប្រឡាយ ចេញច្បាប់ ធ្វើការប្រឡង ឧបត្ថម្ភបន្ទូរបន្ថយដល់ការថែរក្សាចំពោះអ្នកជំងឺ ចងក្រងផែនទីនិងសៀវភៅប្រវត្តិសាស្រ្ត ហើយដាក់ឥទ្ធិពលលើកម្ពុជានិងឡាវ ។ យ៉ាងណាក៏ដោយការរៀបចំទាំងនោះមិនគ្រប់គ្រាន់ ដើម្បីបាននូវភាពជឿនលឿនក្នុងយុគសម័យថ្មីនៃវិទ្យាសាស្រ្ត បច្ចេកវិទ្យា ឧស្សាហកម្ម និងពាណិជ្ជកម្ម ហើយនិងនយោបាយអន្តរជាតិឡើយ ជាពិសេសនៅពេលប្រឈមមុខជាមួយកងទ័ពអឺរ៉ុបប្រកប ដោយឧត្តមភាពខាងបច្ចេកវិទ្យា ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើតំបន់នេះ ។ រាជវង្សង្វៀនជាធម្មតាត្រូវបានគេស្តីបន្ទោស ចំពោះការស្រុតចុះធ្វើទំនើបកម្មប្រទេស ក្នុងពេលរាំងទប់ស្កាត់ការធ្វើអាណានិគមបារាំងនៅចុងសតវត្សទី១៩ ។

## ៦.១. <u>ការលុកលុយឈ្លានពានរបស់បារាំង</u>

ស្ថិតក្រោមរាជបញ្ជានៃព្រះចៅ**ណាប់ប៉ូឡេអុង**ទី៣នៃប្រទេសបារាំង (Napoleon) សំពៅកំភ្លើងបារាំងក្រោមការដឹកនាំរបស់ **រីហ្គូលត៍ ដឺ ហ្សង់នូលី** (Rigault de Genouilly) បានវាយប្រហារកំពង់ផែ **ដា ណាង** (Đà Nẵng) ក្នុងឆ្នាំ១៨៥៨ បង្កឲមានការបំផ្លាញសំខាន់ៗ នៅតែបរាជ័យគ្មានកន្លែងឈរជើងជាបន្តបន្ទាប់ ក៏នៅតែរងទុក្ខវេទនាដោយសារតែជំងឺ នៅតំបន់ក្តៅហើយសើមទៀត ។ ដឺ ហ្សង់នូលី បានចេញសំពៅទៅត្បូងនិងកាន់កាប់ទីក្រុង **គា ឌិញ** (Gia Định) ដែលមានការពារមិនរឹងមាំ (សម័យបច្ចុប្បន្ន ទីក្រុង **ហូ ជី មិញ**) ។ ពីឆ្នាំ១៨៥៩ដល់ ១៨៦៧ កងទ័ពបារាំងបានពង្រីកការគ្រប់គ្រងរបស់ពួកគេទៅ លើខេត្តទាំងប្រាំមួយតាមតំបន់ដីសណ្តទន្លេមេគង្គ ហើយបានបង្កើតអាណានិគមដែលគេស្គាល់ថាជា**កូសាំងស៊ីន** ។ ពីរបីឆ្នាំក្រោយមកទៀត កងទ័ពបារាំងបានឈរជើងនៅលើដីវៀតណាមខាងជើង (ដែលគេហៅថា**តុងកឹង**) ហើយកាន់កាប់បាន ហានណូយពីរដងក្នុងឆ្នាំ ១៨៧៣ និង១៨៨២ ។ ពួកបារាំងបានរៀបចំថែរក្សាតុងកឹង ក្នុងកណ្តាប់ដៃរបស់ពួកគេ ទោះបីជាទាំងពីរលើក មេបញ្ជាការកំពូលៗរបស់ពួកគេ **ផ្រង់ស៊ីស ហ្កាញ៉េ** (Francis Garnie)និង**ហង់រី រីវៀរ** (Henri Rivière)ត្រូវបានពួកស្ទាក់វាយនិងសម្លាប់ចោលក៏ដោយ ។ បារាំងបានក្តោបក្តាប់អំនាចលើប្រទេសវៀតណាមទាំងមូលបន្ទាប់ពីសង្គ្រាមចិន-បារាំង (១៨៨៤-១៨៨៥)ហើយ ។ សហភាពឥណ្ឌូចិន ត្រូវបានបង្កើតឡើងក្នុងខែតុលា ១៨៨៧ពី អណ្ណាម (ទ្រុង គឺ=Trung Kỳ,វៀតណាមកណ្តាល) តុងកឹង (បាក់ គឺ=Bắc Kỳ, វៀតណាមខាងជើង) កូសាំងស៊ីន (ណាម គឺ=Nam Kỳ,វៀតណាមខាងត្បូងនិងកម្ពុជាជាមួយឡាវដែលបានបញ្ចូលក្នុងឆ្នាំ១៨៩៣) ។ នៅក្នុងសហភាពឥណ្ឌូចិន កូសាំងស៊ីនមានឋានៈជាអាណានិគម អណ្ណាមជារដ្ឋក្រោមអាណាព្យាបាលដែលមានតែឈ្មោះដែលរាជវង្សង្វៀននៅតែគ្រប់គ្រង និងតុងកឹងមានអភិបាលបារាំងម្នាក់ ដែលមានអភិបាលកិច្ចក្នុងស្រុកដំណើរការដោយមន្ត្រីៗវៀតណាម ។

បន្ទាប់ពី **គា ឌិញ** (Gia Định) ធ្លាក់ទៅកងទ័ពបារាំង ចលនាតស៊ូវៀតណាមជាច្រើនបានផ្ទុះឡើងក្នុងតំបន់ដែលបានកាន់កាប់ហើយ ខ្លះបានដឹកនាំដោយអតីតមន្ត្រីរាំងមួយភាគ ដូចជា **ទ្រឿង ឌិញ** (Trương Định) ខ្លះទៀតដោយពួកកសិករស្រែចម្ការដូចជា **ង្វៀន ទ្រុង ទ្រុក** (Nguyễn Trung Trực) ដែលជាអ្នកពន្លិចកប៉ាល់កាំភ្លើងបារាំងឡឺអេះស្ប៉ឺរ៉ង់សេ ដោយប្រើប្រាស់ក្បួនទ័ពព្រៃ ។ នៅភាគខាងជើងចលនាភាគច្រើនបំផុតដឹកនាំ ដោយអតីតមន្ត្រីៗរាំងហើយបានបន្តជាច្រើនទសវត្ស ដែលមាន ការប្រឆាំងរបស់**ផាន់ ឌិញ ភុង** (Phan Đình Phùng)នៅភាគកណ្តាលប្រទេសវៀតណាមរហូតដល់ឆ្នាំ១៨៩៥ ។ នៅប្រជុំភ្នំភាគខាងជើង អតីតមេដឹកនាំចោរព្រៃ **ហួង ហួ ថាម**




ទាហានបារាំងកំពុងតែវាយប្រយុទ្ធ
នឹងពួកចាញ់នៅឯឡាង សឺន (Lạng Sơn) ១៨៨៥

(Hoàng Hoa Thám)បានប្រយុទ្ធប្រឆាំងរហូតដល់ឆ្នាំ១៩១១ ។ ថៃមពីនេះព្រះចៅអធិរាជង្វៀន វ៉ៃជំទង់ **ហាម ងី** បានចាកចេញពីព្រះបរមរាជវាំងអធិរាជនៅហ៊្វ (Huế) ក្នុង១៨៨៥ជាមួយសម្ដេចរាជានុសិទ្ធិ **តុន ថាត់ ធុយយិត** (Tôn Thất Thuyết) ហើយបានចាប់ផ្ដើម **កាន់ វឿង** (Cần Vương) រឺ ***សង្គ្រោះស្ដេច*** ជាចលនាមួយ ខិតខំប្រមូលកម្លាំងប្រជាជនដើម្បីតស៊ូនឹងពួកបារាំង ។ ទ្រង់ត្រូវចាប់បានក្នុងឆ្នាំ១៨៨៨ ហើយបាននិរទេសព្រះកាយទៅ **អាល់សេរីបារាំង** (French Algeria) ។ ប៉ុន្មានទសវត្សក្រោយមកទៀត ស្ដេចង្វៀនពីរអង្គទៀត **ថាញ់ ថាយ** (Thành Thái)និង **ឌុយ តាន** (Duy Tân)ក៏ត្រូវនិរទេសខ្លួនទៅអាហ្វ្រិកកាចំពោះការមាននិន្នាការប្រឆាំងបារាំងជាច្រើនដង ។ អ្នកចាស់ៗត្រូវបានដកចេញដោយលេសដែលមិនសមហេតុផល ហើយ ឌុយ តានត្រូវបានចាប់ខ្លួនដោយការរួមគំនិតជាមួយមន្ត្រីម្នាក់ **ត្រាន់ កាវ វ៉ាន់** (Tran Cao Van) ដែលព្យាយាមផ្ដើមការបះបោរ ។

## ៦.២. <u>សតវត្សទី២០</u>

នៅដើមសតវត្សទី២០ ពួកអ្នកស្នេហាជាតិវៀតណាមបានដឹងថា ពួកគេមិនអាចកម្ចាត់បារាំងចេញដោយគ្មានទំនើបកម្មឡើយ ។ ដោយការយល់ដឹងអំពីទស្សនវិជ្ជាលោកខាងលិច ពួកគេមានបំណងបង្កើតឡើងសាធារណរដ្ឋមួយពឹងលើឯករាជ្យភាព ដែលងាកចេញពីគំនិតរាជានិយមនៃចលនា **កាន វឿង** ។ ការធ្វើឲរុស្ស៊ីបរាជ័យដោយសារប្រទេសជប៉ុនក្នុងសង្គ្រាមរុស្ស៊ី-ជប៉ុនបានធ្វើជាឧទាហរណ៍ដ៏ឥតខ្ចោះ នៃទំនើបកម្មដែលជួយប្រទេសអាស៊ីមួយនេះ កម្ចាត់ចក្រភពអឺរ៉ុប ដែលប្រកបដោយឥទ្ធិពលបាន ។



ផាន់ បូយ ចៅ (Phan Boi Chau)

នោះហើយបានបំផុសចលនាទំនើបកម្មស្របគ្នាពីរ ។ លើកទីមួយគឺចលនា (***ដំនើរទៅភាគខាងកើត***) "**ដុង ឌូ**" (Đông Du) ចាប់ផ្ដើមក្នុងឆ្នាំ១៩០៥ ដោយ **ផាន់ បូយ ចៅ** (Phan Bội Châu) ។ ផែនការរបស់លោកចៅគឺត្រូវបញ្ជូននិសិត្សវៀតណាមទៅជប៉ុន ដើម្បីរៀនជំនាញថ្មីៗ ដូច្នេះក្នុងពេលអនាគត ពួកគេអាចដឹកនាំការបះបោរប្រដាប់អាវុធដ៏ជោគជ័យប្រឆាំង នឹងពួកបារាំង ។ ជាមួយគ្នានេះដែរព្រះអង្គម្ចាស់ **កឿង ដេ** (Cường Để) ព្រះអង្គបានចាប់ផ្ដើមអង្គការពីរនៅជប៉ុន:***ឌុយ តាន ហូយ*** (Duy Tân Hội) និងវៀតណាម ***កុង ហៀន ហូយ*** (Việt Nam Công Hiến Hội) ។ ដោយសារតែការដាក់សម្ពាធការទូតរបស់បារាំង ជប៉ុនក្រោយមកបាននិរទេសលោកចៅទៅចិនវិញ ។


ផាន់ ជូ ទ្រិញ (Phan Chu Trinh)

**ផាន់ ជូ ទ្រិញ** (Phan Chu Trinh) ជាអ្នកជ្រោមជ្រែងការតស៊ូតាមបែបសន្តិភាពអហិង្សា ដើម្បីទទួលបានឯករាជ្យបានដឹកនាំចលនា (***ទំនើបកម្ម***) ***ឌុយ តាន*** (Duy Tân) លើកទីពីរ ។ លោកបានសង្កត់ធ្ងន់លើគំរូការអប់រំមនុស្សដ៏ច្រើនសន្ធឹក ធ្វើទំនើបកម្មប្រទេស ជំរុញលើកតំកើងការយោគយល់គ្នា និងការអធ្យាស្រ័យរវាងជនជាតិបារាំងនិងវៀតណាម ហើយនិងការដោះដូរអំណាចគ្នាដោយសន្តិវិធី ។

ផ្នែកដំបូងនៃសតវត្សទី២០ក៏បានមើលឃើញផងដែរ នូវការរីកចំរើនលក្ខណៈអក្ខរក្រម ***ខ្វឿក ង៉ូ*** (Quốc Ngữ) រ៉ូម៉ាំងសម្រាប់ភាសាវៀតណាម ។ អ្នកស្នេហាជាតិវៀតណាមបានស្គាល់នូវសក្តានុពលនៃ ***ខ្វឿក ង៉ូ*** ជាឧបករណ៍ដ៏មានប្រយោជន៍ដើម្បីកាត់បន្ថយអនក្ខរកម្មយ៉ាងលឿន និងអប់រំមនុស្សបានចំនួនដ៏ច្រើនសន្ធឹក ។ តួអក្សរចិនប្រពៃណី រឺតួអក្សរ **ណូម** (Nôm)ត្រូវបានឃើញថាក្រវិចក្រវៀនពេក និងពិបាករៀនមែនទែន ។ ការប្រើប្រាស់ពាក្យរាយក្នុងអក្សរសាស្ត្រក៏បានក្លាយជាពេញនិយម ជាមួយនឹងរូបរាងខាងក្រៅ នៃប្រលោមលោកជាច្រើន ល្បីបំផុតគឺប្រលោមលោកទាំងនោះបានពីការគូសវង់ជាវណ្ណគតិ ***ទូ លុក វ៉ាន់ ដួន*** (Tự Lực Văn Đoàn) ។

ពេលនោះពួកបារាំងបានគាបសង្កត់លើចលនាទាំងពីរ ហើយបន្ទាប់ពីសក្ខីកម្មពួកអ្នកបដិវត្តជាច្រើនកំរើកនៅប្រទេសចិននិងរុស្ស៊ី ពួកអ្នកបដិវត្តវៀតណាមបានចាប់ផ្តើមងាកទៅរកផ្លូវគាំទ្របន្ថែមទៀត ដើម្បីផ្លាស់ប្តូរ ។ ផាន់ បូយ ចៅ បានបង្កើតឡើង*សម្ព័ន្ធលើកស្ទួយប្រទេសវៀតណាម* (វៀតណាម ខ្វាង ផាក់ ហួយ = Viet Nam Quang Phuc Hoi) នៅ**គ័ងចូវ** (Guangzhou) ដោយរៀបចំផែនការតស៊ូប្រដាប់អាវុធប្រឆាំងបារាំង ។ ក្នុងឆ្នាំ១៩២៥ ពួកភ្នាក់ងារបារាំងបានចាប់លោកបាននៅ សៀងហៃ ហើយបានជំរុញលោកទៅវៀតណាម ។ ដោយសារតែប្រជាប្រិយភាពរបស់លោក លោកចៅត្រូវបានរួចរស់ពីការប្រហារជីវិត ហើយត្រូវបានចាប់ឃុំខ្លួនក្នុងផ្ទះរហូតដល់មរណភាពរបស់លោកនៅឆ្នាំ១៩៤០ ។ ក្នុងឆ្នាំ១៩២៧ គណបក្សជាតិនិយមវៀតណាម (*Việt Nam Quốc Dân Đảng*) បានយកគំរូតាមគួមិងតាង (Kuomintang)នៅប្រទេសចិន ត្រូវបានបង្កើតឡើង ។ ក្នុងឆ្នាំ១៩៣០ គណបក្សបានផ្តើមការដណ្តើមអំណាច យិន បាយ តាមបែបប្រដាប់អាវុធនៅតុងកឹងដែលជាលទ្ធផល ប្រធានបក្ស **ង្វៀន ថាយ ហុក** (Nguyen Thai Hoc)និងមេដឹកនាំផ្សេងៗមួយចំនួនទៀតត្រូវបានចាប់ និងប្រហារជីវិតដោយម៉ាស៊ីនកាត់ក្បាល ។ **លទ្ធិម៉ាខ** ត្រូវបានបញ្ចូលទៅក្នុងប្រទេសវៀតណាមជាមួយការផុសឡើងនៃគណបក្សកុម្មុយនិស្តដាច់ពីគ្នាបី បក្សកុម្មុយនិស្តឥណ្ឌូចិន បក្សកុម្មុយនិស្តវៀតណាម និងសហភាពកុម្មុយនិស្តឥណ្ឌូចិន បានចូលរួមក្រោយមកទៀតដោយចលនា**ត្រូតស្គី** (Trotsky) ដឹកនាំដោយ **តា ធូ ធៅ** (Tạ Thu Thâu) ។ ក្នុងឆ្នាំ១៩៣០ អង្គការកុម្មុយនិស្តអន្តរជាតិ (កុំមីនតែន = Comintern)បានបញ្ជូន **ង្វៀន អាយ ខ្វឿក** (Nguyễn Ái Quốc) ទៅ ហុងកុង ដើម្បីសម្របសម្រួលក្នុងការបង្រួបបង្រួមបក្សជាច្រើនទៅជាបក្សកុម្មុយនិស្តវៀតណាម ដែលមាន **ច្រាន់ ភូ** (Trần Phú) ជាអគ្គលេខាទីមួយ ។ ក្រោយមកទៀតបក្សបានផ្លាស់ប្តូរឈ្មោះ ទៅជាបក្សកុម្មុយនិស្តឥណ្ឌូចិនវិញជាកំមិនតែនក្រោមការដឹកនាំរបស់ ចូសិផ្ទ ស្តាលីន (Joseph Stalin) មិនអនុគ្រោះដល់គំនិតជាតិនិយមទេ ។ **ង្វៀន អាយ ខ្វឿក** គឺជាអ្នកបដិវត្តឆ្វេងនិយមរស់នៅប្រទេសបារាំងតាំងពីឆ្នាំ១៩១១ ។ លោកបានចូលរួម ក្នុងការស្ថាបនាបក្សកុម្មុយនិស្តបារាំង ហើយក្នុងឆ្នាំ១៩២៤បានធ្វើដំណើរទៅសហភាពសូវៀត ដើម្បីចូលរួមកំមិនតែន ។ តាមរយៈ

ចុងទសវត្សឆ្នាំ១៩២០ លោកបានដើរតួជាភ្នាក់ងារកំមិនតែន ដើម្បីជួយកសាងចលនាកុម្មុយនិស្តនៅអាស៊ីអាគ្នេយ៍។ កំឡុងទសវត្សឆ្នាំ១៩៣០ បក្សកុម្មុយនិស្តវៀតណាមត្រូវបាជម្រះចោលស្ទើរតែអស់ហើយ ក្រោមការសង្កត់សង្កិនរបស់បារាំង ជាមួយនឹងការប្រហារជីវិតមេដឹកនាំកំពូលៗដូចជាលោក**ភូ** (Phú) , **ឡេ ហុង ផុង** (Lê Hồng Phong) និង **ង្វៀន វ៉ាន់ គុ** (Nguyễn Văn Cừ) ។

ក្នុងឆ្នាំ១៩៤០ កំឡុងសង្គ្រាមលោកលើកទី២ ជប៉ុនបានឈ្លានពានឥណ្ឌូចិន ដោយទុកនៅតែរដ្ឋបាលអាណានិគមបារាំងវិចឈីមាននាទីជាអាយ៉ងជប៉ុន ។ ក្នុងឆ្នាំ១៩៤១ **ង្វៀន អាយ ខ្វឿក** (Nguyễn Ái Quốc) ដែលឥឡូវស្គាល់ថាជា ហូ ជី មិញ បានមកដល់វៀតណាមខាងជើង ដើម្បីបង្កើតរណសិរ្ស**វៀតមិញ** (Việt Minh) ទំរង់កាត់របស់ ***វៀតណាម ដុក លាបដុង មិញ ហូយ*** (Việt Nam Độc Lập Đồng Minh Hội) មានន័យថា (សម្ព័ន្ធដើម្បីឯករាជ្យវៀតណាម) ។ រណសិរ្សវៀតមិញ ត្រូវបានគេស្មានថាជាក្រុមឆ័ត្ររបស់គ្រប់បក្សទាំងអស់ វាយដណ្តើមឯករាជ្យឲវៀតណាម ប៉ុន្តែវាត្រូវបានត្រួតត្រាដោយបក្សកុម្មុយនិស្ត ។ ពួកវៀតមិញមានកងកម្លាំងប្រដាប់អាវុធសុភាពរាបសារ ហើយកំឡុងពេលសង្គ្រាមបានធ្វើការ ជាមួយការិយាល័យសេវាយុទ្ធសាស្ត្រអាមេរិកដើម្បីប្រមូលព័ត៌មានសម្ងាត់នៅជប៉ុន ។ ពីប្រទេសចិន គណបក្សវៀតណាមដែលមិនមែនកុម្មុយនិស្តផ្សេងទៀតក៏បានចូលរួមនឹងពួកវៀតមិញដែរ ហើយបានបង្កើតឡើងនូវកងកម្លាំងប្រដាប់អាវុធ ជាមួយការចាកត្រលប់មកពីពួកគួមិងតាងវិញ។

## ៧. <u>ឯករាជ្យ និងសង្គ្រាម</u>

លោកប្រធានាធិបតីអាមេរិកាំង រ៉ូស្វែលថ៍ និងលោកឧត្តមសេនីយ ស្ទីលវែលបានធ្វើដោយផ្ទាល់ នូវការចរចារយ៉ាងដាច់ខាតថាពួកបារាំងមិនត្រូវស្នើសុំសហភាពឥណ្ឌូចិន (សម័យថ្មី វៀតណាម កម្ពុជានិងឡាវ) វិញបន្ទាប់ពីសង្គ្រាមបានបញ្ចប់ឡើយ ។ លោករ៉ូស្វែលថ៍បានផ្តល់ឲ**ចាង ខាយចៀក** (Chiang Kai-shek) នូវតំបន់ឥណ្ឌូចិនទាំងមូលឲ នៅក្រោមការគ្រប់គ្រងរបស់ចិន ។ ដែលនិយាយថា ចាង ខាយចៀកបានឆ្លើយតបថា៖ ***ត្រួតត្រាតែមិនឆ្លៀតឱកាស!*** ។[៧]

បន្ទាប់ពីសង្គ្រាម កងទ័ពចិន២០០,០០០នាក់ ក្រោមការដឹកនាំរបស់ឧត្តមសេនីយ **លូ ហាន** ដែលបានបញ្ជូនដោយ **ចាង ខាយចៀក** ទៅលុកភាគខាងជើងឥណ្ឌូចិន នៅខ្សែស្របខាងជើងទី១៦ ដើម្បីទទួលការសុំចុះចាញ់របស់កងកម្លាំងជប៉ុន ដែលកំពុងតែកាន់កាប់ និងនៅសេសសល់រហូតដល់ឆ្នាំ១៩៤៦ ។[៨] ពួកចិនបានប្រើប្រាស់គណបក្សជាតិនិយមវៀតណាម (VNQDD) សាខាគួមិងតាងចិននៅវៀតណាម ដើម្បីបង្កើនឥទ្ធិពលនៅឥណ្ឌូចិន និងដាក់សម្ពាធដល់បច្ចាមិត្ររបស់ខ្លួន ។[៩] ចាង ខាយចៀក បានគំរាមពួកបារាំងជាមួយសង្គ្រាមដោយការឆ្លើយតបទៅនូវការធ្វើកលល្បិចដោយឲពួកបារាំងនិងហូ ជីមិញ ប្រឆាំងគ្នា ដែលបង្ខំឲពួកគេមករកកិច្ចព្រមព្រៀងសន្តិភាព និងបង្ខំឲបារាំងប្រគល់ឲនូវការសម្បទានទាំងអស់ នៅប្រទេសចិននិងប្រកាសឡើងវិញឯកសិទ្ធិនៅក្រៅដែនដី ក្នុងការដោះដូរចំពោះការដកទ័ពពីភាគខាងជើងឥណ្ឌូចិន ហើយអនុញ្ញាតឲទ័ពបារាំងគ្រប់គ្រងតំបន់នោះឡើងវិញ ចាប់ផ្តើមក្នុងខែមិនា១៩៤៦ ។[១០][១១][១២][១៣]

ក៏ប៉ុន្តែ ពួកបារាំងភ្លាមៗបានអះអាងអំណាចឡើងវិញ ដែលពួកគេបានប្រគល់ឲពួកជប៉ុន ហើយសង្គ្រាមឥណ្ឌូចិនលើកទីមួយ (១៩៤៦-៥៤)ក៏បានចាប់ផ្ដើមឡើង ។ ការគ្រប់គ្រងរបស់បារាំងបានបញ្ចប់នៅថ្ងៃ ៧ឧសភា ១៩៥៤ នៅពេលដែលកងកម្លាំងរបស់វៀតណាមធ្វើឲពួកបារាំងបរាជ័យនៅ**ដៀន បៀន ភូ** (Dien Bien Phu) ។ សន្និសិតសឺណែវឆ្នាំ១៩៥៤បានបន្សល់ឲវៀតណាមនូវប្រទេសដែលបែងចែកគ្នា ដែលមានរដ្ឋាភិបាលកុម្មុយនិស្តរបស់ ហូ ជីមិញគ្រប់គ្រងនៅភាគខាងជើងពីហានណូយ និងរបប **ង៉ោ ឌិញ ឌៀម** (Ngo Dinh Diem) ដែលគាំទ្រដោយសហរដ្ឋអាមេរិកគ្រប់គ្រងនៅភាគខាងត្បូងពីសៃហ្គន (ក្រោយមកទៀតជាទីក្រុង ហូ ជីមិញ) ។

ជាលទ្ធផលនៃសង្គ្រាមឥណ្ឌូចិនលើកទីពីរ (១៩៥៤-៧៥) **វៀតកុង** និងកងទ័ពប្រជាជនវៀតណាម (PAVN)ជារឿយៗ ប្រើកម្លាំងពីភាគខាងជើង ដើម្បីបង្រួបបង្រួមវៀតណាមក្រោមការដឹកនាំតាមបែបកុម្មុយនិស្ត ។ ក្នុងការប៉ះទង្គិចនេះ ពួកបដិវត្តជាមួយការគាំទ្រខាងព័ស្តភានិងកងទ័ពពីចិន និងសហភាពសូវៀតនៅទីបំផុតបានវាយកម្ចាត់កងទ័ពសាធារណរដ្ឋវៀតណាម ដែលប្រមើលដើម្បីរក្សាឯករាជ្យភាពវៀតណាមខាងត្បូង ជាមួយការគាំទ្រពីយោធាស.រ.អា. ដែលកម្លាំងកងទ័ពរបស់ពួកគេដល់ទៅ៥៤០,០០០នាក់កំលុងពេលការវាយលុកចិត ដែលនាំមុខដោយពួកកុម្មុយនិស្តក្នុងឆ្នាំ១៩៦៨ ។ ពួកខាងជើងមិនធ្វើតាមលក្ខ័ណ្ឌកិច្ចព្រមព្រៀងប៉ារីស១៩៧៣ទេ ដែលផ្សះផ្សារសង្គ្រាមជាផ្លូវការដោយកោះហៅ ដើម្បីធ្វើការបោះឆ្នោតដោយសេរីនៅភាគខាងត្បូង និងការបង្រួបបង្រួមដោយសន្តិភាពឡើងវិញ ។ ពីរឆ្នាំបន្ទាប់មកការដកទ័ពរបស់ស.រ.អា.ក្នុងឆ្នាំ១៩៧៣ សៃហ្គន រដ្ឋធានីនៃវៀតណាមខាងត្បូងបានធ្លាក់ក្នុងដៃពួកកុម្មុយនិស្ត និងទាហានវៀតណាមខាងត្បូងបានសុំចុះចាញ់នៅថ្ងៃ ៣០មេសា ១៩៧៥។ ក្នុងឆ្នាំ១៩៧៦ រដ្ឋាភិបាលបង្រួបបង្រួមវៀតណាមបានប្ដូរឈ្មោះសៃហ្គនទៅជា ទីក្រុងហូ ជីមិញវិញ ជាកិត្តិយសដល់មេដឹកនាំកុម្មុយនិស្តសម័យសង្គ្រាមដែលបានស្លាប់នៅ ខែ កញ្ញា ១៩៦៩ ។ ជនជាតិវៀតណាមបានប៉ាន់ប្រមាណសរុបថាជីវិត ស្ទើរតែ៣លាននាក់បានបាត់បង់ និងរបួស៤លាននាក់កំឡុងពេលការពាក់ព័ន្ធ របស់សហរដ្ឋអាមេរិកក្នុងសង្គ្រាមនោះ ។

## ៨. <u>សង្គមនិយមក្រោយឆ្នាំ១៩៧៥</u>

នៅសម័យក្រោយឆ្នាំ១៩៧៥ ភ្លាមបានលេចឡើងដែលនូវប្រជាប្រិយភាពនិងប្រសិទ្ធភាព នៃនយោបាយបក្សកុម្មុយនិស្តវៀតណាម (VCP) ដែលមិនបានពន្យារពេលដ៏សំខាន់ដល់ផែនការកសាងជាតិ ក្នុងសម័យសន្តិភាពជាច្រើនរបស់បក្សឡើយ ។ ដោយកំពុងបង្រួបបង្រួមខាងជើងនិងខាងត្បូងតាមបែបនយោបាយ បក្សកុម្មុយនិស្តវៀតណាមនៅតែត្រូវធ្វើសមាហរណកម្មពួកគេទាំងសង្គម និងសេដ្ឋកិច្ច ។ ក្នុងកិច្ចការនេះ អ្នកបង្កើតនយោបាយបក្សកុម្មុយនិស្តវៀតណាមត្រូវប្រឈមមុខ ជាមួយនឹងការតស៊ូរបស់ពួកភាគខាងត្បូង ចំពោះការប្ដូរទៅជាកុម្មុយនិស្តវិញ ក៏ដូចគ្នាការស្អប់គ្នាខាងប្រពៃណី ដែលដើបឡើងពីភាពផ្សេងគ្នាខាងវប្បធ៌ម និងប្រវត្តិសាស្ត្ររវាងខាងជើងនិងខាងត្បូង ។ ច្រើនជាងមួយលាននាក់នៃពួកខាងត្បូង ក្នុងនោះប្រហែល៥៦០,០០០នាក់ជា“ប្រជាជនទូក” បានភៀសខ្លួនចេញពីប្រទេសភ្លាមបន្ទាប់ពីពួកកុម្មុយនិស្តកាន់កាប់ ដោយភ័យខ្លាចការធ្វើទុក្ខបុកម្នេញ និងការរឹបអូសដីធ្លី និងការរកស៊ីរបស់ពួកគេ ។ ជនជាតិវៀតណាមប្រហែលមួយលាននាក់ត្រូវតាំងលំនៅឡើងវិញ ដើម្បីដីធ្លីទំនេរមុនៗ ដែលហៅថា“តំបន់សេដ្ឋកិច្ចថ្មី”សំរាប់រៀនសូត្រឡើងវិញ ។

វិធានការលុបបំបាត់កំអែលមូលធននិយមក្រោយសង្គ្រាមយ៉ាងយង់ឃ្នង នៅភាគខាងត្បូងបាននាំទៅ ដល់ការធ្លាក់ចុះសេដ្ឋកិច្ច កំឡុងទសវត្សឆ្នាំ១៩៨០ ។ ជាមួយនឹងសេដ្ឋកិច្ចស្ថិតក្នុងភាពច្របូកច្របល់ រដ្ឋាភិបាលវៀតណាមបានប្ដូរទិសដៅ ហើយបានទទួលយកនយោបាយសមស្រប ដែលបានធ្វើជាស្ពានលើទស្សនវិស័យផ្ទុយគ្នានៃពួកការណនិយម និងពួកអ្នកកាន់ប្រពៃណីកុម្មុយនិស្តនិយម ។ ក្នុងឆ្នាំ១៩៨៦ **ង្វៀន វ៉ាន់ លិញ** (Nguyen Van Linh) ដែលត្រូវបានតំឡើង ជាអគ្គលេខាធិការបក្សកុម្មុយនិស្តវៀតណាមនៅឆ្នាំបន្ទាប់ បានផ្ដើមយុទ្ធនាការដើម្បីការផ្លាស់ប្ដូរសាជាថ្មីខាននយោបាយ និងសេដ្ឋកិច្ច (**ដូយ ម៉ូយ** = Doi Moi) ។ នយោបាយរបស់លោក ត្រូវបានបង្ហាញចរិកលក្ខណៈនូវបទពិសោធន៍នយោបាយ និងសេដ្ឋកិច្ចដែលស្រដៀងនឹងរបៀបវារៈកំនែទំរង់ ដែលកើតឡើងតំណាលគ្នា ដែលបានទទួលធ្វើនៅសហភាពសូវៀត ។ ដោយឆ្លុះបញ្ចាំងនូវគំនិតនៃការស្រុះស្រួលគ្នាខាងនយោបាយ វៀតណាមបានឈប់បន្តិចម្ដងនូវកិច្ចប្រឹងប្រែងការអប់រំឡើងវិញ ។ រដ្ឋាភិបាលក៏បានបញ្ឈប់ការលើកទឹកចិត្ត ដល់សហករណ៍កសិកម្ម និងឧស្សាហកម្មដែរ ។ កសិករត្រូវបានអនុញ្ញាតឲភ្ជួរដីធ្លីកម្មសិទ្ធិឯកជន ក្បែរដីកម្មសិទ្ធិរដ្ឋ ហើយនៅឆ្នាំ១៩៩០ រដ្ឋាភិបាលបានអនុម័តច្បាប់លើកទឹកចិត្ត ដល់ការបង្កើតជំនួញឯកជន ។ ដោយរួមផ្សំភាពលំបាកខាងសេដ្ឋកិច្ចគឺជាការប្រកួតប្រជែងផ្នែកយោធាថ្មី ។ ក្នុងចុងទសវត្សឆ្នាំ១៩៧០ ប្រទេសពីរកម្ពុជានិងចិនបានដាក់ការគំរាមកំហែងដល់វៀតណាម ។ ការទាស់គ្នាជាច្រើនរវាងពួកកុម្មុយនិស្តវៀតណាម និងកម្ពុជានៅតាមព្រំដែនរួម ដែលចាប់ផ្ដើមស្ទើរតែភ្លាមៗ បន្ទាប់ពីការបង្រួបបង្រួមវៀតណាមឡើងវិញក្នុងឆ្នាំ១៩៧៥ ។ ដើម្បីទប់ទល់នឹងការគំរាមកំហែងវៀតណាម បានចូលលុកលុយកម្ពុជានៅខែធ្នូ ១៩៧៨ ហើយបានលុករុលដល់ភ្នំពេញរដ្ឋធានីកម្ពុជាដោយកម្ទាត់ នូវរបបកុម្មុយនិស្តខ្មែរក្រហមដែលកំពុងកាន់អំណាច និងបញ្ចូលការត្រួតត្រាខាងកងទ័ពជាសម្ងាត់បន្តយ៉ាងយូរ នៅក្នុងប្រទេសនេះ ។



សាសនាទូត អេនដ្រិច ម៉េចសេន (Andrej Majcen) និងសម្ដេចសង្ឃរាជ (គ្រិស្តសាសនា) ក្នុងការប្រារព្ធពិធីមួយនៅសៃហ្គន ប្រហែលឆ្នាំ១៩៧០នៅវៀតណាមត្បូង) ។ *„យើងស្គាល់គាត់ គាត់គឺ ជាគ្រូនិងព្រះសង្ឃរាជ របស់យើង”!*

## ៩. <u>ការផ្លាស់ប្ដូរឈ្មោះ</u>

សម្រាប់ភាគច្រើនបំផុតនៃប្រវត្តិសាស្ត្ររបស់ប្រទេស ព្រំដែនភូមិសាស្ត្រនៃវៀតណាមសព្វថ្ងៃនេះ បានគ្របដណ្ដប់នូវប្រទេសជាតិផ្សេងៗ៣ទៀតៈប្រទេសវៀតណាម **ប្រទេសចាម**និងជាផ្នែកមួយនៃ**ចក្រភពខ្មែរ** ។

ប្រទេសវៀតដើមឡើយនៅតំបន់ដីសណ្ដទន្លេក្រហមនៅវៀតណាមខាងជើងសព្វថ្ងៃនេះ និងបានពង្រីកវិសាលភាពប្រវត្តិសាស្ត្រ របស់ប្រទេសមកដល់ព្រំដែនថ្មីៗនេះ ។ ប្រទេសបានឆ្លងកាត់ការប្ដូរឈ្មោះជាច្រើន ដែលមានតែដាយវៀតទេបានប្រើយូរជាងគេបំផុត ។ ខាងក្រោមគឺជាការសង្ខេបឈ្មោះ៖

| សម័យ | ឈ្មោះប្រទេស | រយៈកាល | ព្រំប្រទល់ |
|---|---|---|---|
| រាជវង្ស ហុង បាង | វ៉ាន ឡាង | ពីមុនឆ្នាំ ២៥៨ម.គ. | គ្មានការកត់ត្រាពិតប្រាកដអំពីព្រំដែនរបស់ប្រទេស ។ រឿងនិទានមួយចំនួនបានអះអាងថាព្រំប្រទល់ខាងជើង ប្រហែលជាដល់ទន្លេយ៉ាងសេ ។ ក៏ប៉ុន្តែ សៀវភៅអត្ថបទប្រវត្តិសាស្ត្រសម័យថ្មីភាគច្រើននៅប្រទេសវៀតណាម អះអាងថាដីសណ្ដទន្លេក្រហម ជាទឹកដីកំណើតនៃវប្បធ៌មឡាក់ វៀត ។ |
| រាជវង្សថាច់ | ឪ ឡាក់ | ២៥៨ម.គ.-២០៧ម.គ. | ដីសណ្ដទន្លេក្រហមនិងជំនាប់គ្នានឹងតំបន់ភ្នំខាងជើងនិងខាងលិច ។ |
| រាជវង្សទ្រៀវ | ណាម វៀត | ២០៧ម.គ.-១១១ម.គ. | ឪ ឡាក់ គ័ងតុងនិងគ័ងស៊ី ។ |
| ការត្រួតត្រារបស់រាជវង្សហានចិន | គាវ ឈី (ជាវ ជឺ) | ១១១ម.គ.-៥៤៤គ.ស. | បច្ចុប្បន្នភាគខាងជើង និងដើមខាងជើងនៃវៀតណាម(ព្រំដែនខាងត្បូងបានពង្រីកចុះមកក្រោម ដល់ដីសណ្ដ ទន្លេម៉ា និងទន្លេកា) ។ |
| រាជវង្សចិនបន្តបន្ទាប់ | ជាទូទៅហៅថា គាវ ចូវ ។វ៉ាន សួន កំឡុងឯករាជ្យបានកន្លះសតវត្សនៃអតីតរាជវង្សលី ។ ត្រូវបានដាក់ឈ្មោះជាផ្លូវការ អណ្ណាម ដោយរាជវង្សថាងចិន តាំងពីឆ្នាំ៦៧៩គ.ស. ។ | ៥៤៤គ.ស.-៩៦៧គ.ស. | ដូចខាងលើដែរ ។ |
| រាជវង្សឌិញ និង ឡេដំបូង | ដាយ កូ វៀត | ៩៦៧គ.ស.-១០០៩គ.ស. | ដូចខាងលើដែរ ។ |
| រាជវង្សលី និង ច្រាន់ | ដាយ វៀត | ១០១០គ.ស.-១៤០០គ.ស. | ព្រំដែនខាងត្បូងលាតចុះមកតំបន់ហ៊ូសព្វថ្ងៃនេះ ។ |
| រាជវង្សហូ | ដាយ វៀត | ១៤០០គ.ស.-១៤០៧គ.ស. | ដូចខាងលើដែរ ។ |
| រាជវង្សឡេ ម៉ាក់ ពួកលោកម្ចាស់ទ្រិញ&ndash ង្វៀន រាជវង្ស តៃ សឺន | ដាយ វៀត | ១៤២៨គ.ស.-១៨០២គ.ស. | បានលាតសន្ធឹងបន្តិចម្ដងៗមកដល់ព្រំដែនវៀតណាមបច្ចុប្បន្ននេះ ។ |
| រាជវង្សង្វៀន | វៀតណាម | ១៨០២គ.ស.-១៨៨៧គ.ស. | វៀតណាមបច្ចុប្បន្នបូកដែនដីដែលបានកាន់កាប់ខ្លះក្នុងប្រទេសឡាវនិងកម្ពុជា ។ |
| អាណានិគមបារាំង | សហភាពឥណ្ឌូចិន, បញ្ចូលនូវកូសាំងស៊ីន (វៀតណាមខាងត្បូង) អណ្ណាម (វៀតណាមកណ្ដាល) តុងកឹង (វៀតណាមខាងជើង) កម្ពុជា និងឡាវ ។ | ១៨៨៧គ.ស.-១៩៤៥គ.ស | វៀតណាមបច្ចុប្បន្ន ឡាវនិងកម្ពុជា ។ |
| ឯករាជ្យ | វៀតណាម(ជាមួយរដ្ឋដ៏ទៃៗ ដូចជា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម, រដ្ឋវៀតណាម, សាធារណរដ្ឋវៀតណាម សាធារណរដ្ឋសង្គមនិយមវៀតណាម) | សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (១៩៤៥-១៩៧៦) រដ្ឋវៀតណាម (១៩៤៩-១៩៥៦) សាធារណរដ្ឋវៀតណាម (១៩៥៦-១៩៧៥ នៅវៀតណាមខាងត្បូង) សាធារណរដ្ឋសង្គមនិយមវៀតណាម (១៩៧៦-បច្ចុប្បន្ន) | វៀតណាមបច្ចុប្បន្ន ។ |

ស្ទើរតែគ្រប់រាជវង្សវៀតណាមទាំងអស់បានដាក់ឈ្មោះ តាមត្រកូលរបស់ស្តេច មិនដូចពួករាជវង្សចិនទេ ដែលឈ្មោះរបស់រាជវង្សត្រូវបានបង្ហាញ ដោយស្ថាបនិករាជវង្សនិងជារឿយៗប្រើជាឈ្មោះប្រទេស ។

វានៅតែមានបញ្ហាជជែកតទល់គ្នាថាតើរាជវង្ស **ហុង បាង**គឺពិតជាមែនរឺក៏ជារាជវង្សសំគាល់តំណាង៥ ប្រទេស ឡាក់ វៀត មុនពេលបានកត់ត្រាក្នុងប្រវត្តិសាស្ត្រ ។ រាជវង្ស**ថាច់ ទ្រៀវ** អតីតលី **ង៉ោ ឌិញ ឡេ**ដំបូង **លី ថ្រាន់ ហូ ឡេ ម៉ាក់, តៃ សឺន** និង**ង្វៀន**ជាធម្មតាត្រូវបានចាត់ទុក ដោយពួកអ្នកប្រវត្តិវិទូថាជាក្រុមរាជវង្សផ្លូវការ ។ ***រាជវង្ស តៃ សឺន*** របស់ **ង្វៀន ហ៊ូ** ផ្ទុយមកវិញគឺជាឈ្មោះដែលបង្កើតឡើង ដោយពួកអ្នកប្រវត្តិវិទូដើម្បីចៀសវាងការភាន់ច្រលំ ជាមួយរាជវង្សង្វៀនរបស់ **ង្វៀន អាញ់** ។

ឯកសារយោង

ដកស្រង់ចេញពីសព្វវចនាធិប្បាយសេរី វីគីភីឌា

http://km.wikipedia.org/wiki/ ប្រវត្តិសាស្ត្រវៀតណាម

1. ↑ ខេននី (Kenny), ហិនរី ជេ.(Henry J.) (២០០២)។ *ស្រមោលនាគរាជ:ការតស៊ូបន្តរបស់វៀតណាមជាមួយចិននិងការជំពាក់ជំពិនដល់នយោបាយការបរទេស ស.រ.អា.*។ របស់លោកប្រាសសី (Brassey)។ ល.ស.ប.អ. 9781574884791។ http://books.google.com/books?id=EWWOKb5t5G0C។ ទំ. ១៨.
2. ↑ ២.០ ២.១ ខេននី ២០០២, p. ២១.
3. ↑ ណេហឺ (Neher), ខ្លាខ ឌី (Clark D.); Ross Marlay (១៩៩៥)។ *ប្រជាធិបតេយ្យនិងការអភិវឌ្ឍនៅអាស៊ីអាគ្នេយ៍៖ជំនោរនៃការផ្លាស់ប្ដូរ*។ ទំ. ១៦២។
4. ↑ ហ្គឺដ អាល់ប្រិចថ៍ (Gerd Albrecht)៖ *ការលើកដីមូលខ្រេខ៥២/៦២៖ការស្រាវជ្រាវថ្មីៗនៃបុរេប្រវត្តិកម្ពុជាតំនក់ឌីអ៊ែផ្គ*
5. ↑ មរណភាព សាសនទូតកាតូលិក, ខែសីហា១៩០៣, សងខាង ២៥៥-២៥៧, ជ្រេបឹហ្គ អ៊ិម ប្រេសហ្គ
6. ↑ ដាវីដសុន (Davidson), ចឺរ៉េមី អេក.ស៊ី.អ៊ែស. (Jeremy H. C. S.); H. L. Shorto (១៩៩១)។ *ភាសាអាស៊ីខាងត្បូង៖ បទនិពន្ធជាកិត្តិយសដល់អេក.អ៊ែល.ស្តូតតូ (H.L. Shorto)*។ ទំ. ៩៥។
7. ↑ បាបារ៉ា វ៉ឺថេម ថាច់មេន (Barbara Wertheim Tuchman) (១៩៨៥)។ *ដំនើរលីលាៈពីទ្រយទៅវៀតណាម*។ រោងពុម្ពរ៉េនដុំ, អាយអិនស៊ី ។។ ទំ. ២៣៥។ ល.ស.ប.អ. 0345308239។ http://books.google.com/books?id=v5YIBtzkIvQC&pg=PA235&dq=chiang+kai-shek+vietnam+Under+no+circumstances&hl=en&ei=hI4OTZGwIcL98Aasn5iVDg&sa=X&oi=book_result&ct=result&resnum=2&ved=0CCgQ6AEwAQ#v=onepage&q=chiang%20kai-shek%20vietnam%20Under%20no%20circumstances&f=false. Retrieved ២០១០-១១-២៨។
8. ↑ ឡូរី អេក. អេដឌីងតុន (Larry H. Addington) (2000)។ *សង្គ្រាមអាមេរិកនៅវៀតណាម៖ប្រវត្តិសាស្ត្រនិទានខ្លី*។ កាសែតសាកលវិទ្យាល័យឥណ្ឌាណា។ ទំ. ៣០។ ល.ស.ប.អ. 0253213606។ http://books.google.com/books?id=iF3MG43x--0C&pg=PA30&dq=chiang+kai-shek+vietnam+french+concessions&hl=en&ei=_Y0OTYTpIsL38Aa2_MiwDg&sa=X&oi=book_result&ct=result&resnum=3&ved=0CC0Q6AEwAg#v=onepage&q=chiang%20kai-shek%20vietnam%20french%20concessions&f=false. Retrieved ២០១០-១១-២៨។
9. ↑ ភិតចឺ ណេវីល (Peter Neville) (2007)។ *ជនជាតិប្រ៊ីតថេននៅវៀតណាម៖ការផ្ដើមនូវមហន្តរាយ ១៩៤៥-៦*។ កាសែតចិត្តវិទ្យា។ ទំ. ១១៩។ ល.ស.ប.អ. 0415358485។ http://books.google.com/books?id=o1t8-EjWyrgC&pg=PA119&dq=chiang+kai-shek+vietnam+french+concessions&hl=en&ei=_Y0OTYTpIsL38Aa2_MiwDg&sa=X&oi=book_res

ult&ct=result&resnum=8&ved=0CEUQ6AEwBw#v=onepage&q=chiang%20kai-shek%20vietnam%20french%20concessions&f=false. Retrieved ២០១០-១១-២៨។

10. ↑ វ៉ាន់ ង្វៀន ឌឿង (២០០៨)។ *សោកនាដកម្មនៃសង្គ្រាមវៀតណាម៖បទវិភាគរបស់អ្នកវេជ្ជការវៀតណាមខាងត្បូងម្នាក់*។ ម៉ាក់ផ្លារលេនដ៍ (McFarland)។ ទំ. ២១។ ល.ស.ប.អ. 0786432853។ http://books.google.com/books?id=pVNaoUu7veUC&pg=PA21&dq=chiang+kai-shek+vietnam+french+concessions&hl=en&ei=_Y0OTYTpIsL38Aa2_MiwDg&sa=X&oi=book_result&ct=result&resnum=9&ved=0CEoQ6AEwCA#v=onepage&q=chiang%20kai-shek%20vietnam%20french%20concessions&f=false. Retrieved ២០១០-១១-២៨។

11. ↑ ស្ទ័ន តូននេសុន (២០១០)។ *វៀតណាមឆ្នាំ១៩៤៦៖សង្គ្រាមចាប់ផ្តើមយ៉ាងម៉េច*។ សារព័តមានសាកលវិទ្យាល័យកាលីផ្វនា។ ទំ. ៤១។ ល.ស.ប.អ. 0520256026។ http://books.google.com/books?id=1I4HOcmE4XQC&pg=PA41&dq=chiang+kai-shek+vietnam+french+concessions&hl=en&ei=_Y0OTYTpIsL38Aa2_MiwDg&sa=X&oi=book_result&ct=result&resnum=2&ved=0CCgQ6AEwAQ#v=onepage&q=chiang%20kai-shek%20vietnam%20french%20concessions&f=false. Retrieved ២០១០-១១-២៨។

12. ↑ អេលីហ្សាបេថ ចេន អេរីងតុន (១៩៩០)។ *សង្គ្រាមវៀតណាមជាប្រវត្តិសាស្ត្រ៖រៀបរៀងដោយ អេលីហ្សាបេថ ចេន អេរីងតុន និង ប៊ី.ជេ.ស៊ី. ម៉ាខ៍ឌីឆធី*។ ក្រុមបោះពុម្ពព្រៃបែគង។ ទំ. ៦៣។ ល.ស.ប.អ. 0275935604។ http://books.google.com/books?id=yQGqQ3LmExwC&pg=PA63&dq=chiang+kai-shek+vietnam+french+concessions&hl=en&ei=_Y0OTYTpIsL38Aa2_MiwDg&sa=X&oi=book_result&ct=result&resnum=4&ved=0CDIQ6AEwAw#v=onepage&q=chiang%20kai-shek%20vietnam%20french%20concessions&f=false. Retrieved ២០១០-១១-២៨។

13. ↑ "គ្រាប់ពូជនៃការប៉ះទង្គិច១៩៤៥-១៩៦០នៃសង្គ្រាមវៀតណាម". កន្លែងប្រវត្តិសាស្ត្រ. ១៩៩៩. http://www.historyplace.com/unitedstates/vietnam/index-1945.html. Retrieved ២០១០-១២-២៨.

14. ↑ Majcen – ustanovitelj salezijanske družbe v Vietnamu. "Poznamo ga, bil je naš magister in patriarh" (មែជសេន ស្ថាបនិកនៃសង្គមសេលេសៀននៅវៀតណាម ។ ពួកយើងស្គាល់លោក លោកគឺជាគ្រូគង្វាលនិងសម្តេចសង្ឃរបស់យើង), បាននិយាយដោយ ផ្ទ្រ. ចន សម្តេចសង្ឃ ង្វៀន វ៉ាន់ ថេម ។ មើល៖ Andrej Majcen, Dobrotna božja sled, Zbornik študijskega dneva ob 100-letnici rojstva Rakovnik, 22. oktobra 2005, (អេនជ្រិច មែជសេន ផ្លូវព្រះមេត្តា សៀវភៅសិក្សារាល់ថ្ងៃឆ្នាំទី១០០ នៃកំណើតរបស់លោកនៅ ថ្ងៃរ៉ាក់កូវនីក២២តុលា២០០៥បោះពុម្ពដោយ៖សាលវ៉េ លូប្លចាណា ២០០៦ ស្លូវ៉េនា ។ ISBN 961-211-354-8